ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំស្តីពីការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំ

## មគ្គុទេសក៍ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅកម្ពុជា

ខែសីហា ឆ្នាំ២០២១

# មាតិកា


បញ្ជីពាក្យកាត់ និងអក្សរកាត់ .................................................................................... 4

បុព្វកថា ................................................................................................................ 7

១. សេចក្ដីផ្ដើម ........................................................................................................ 8

១.១ គោលដៅរួមប្រព័ន្ធ អវប ......................................................................................8

១.២ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមសាលារៀន ..........................................................9

១.២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់..........................................10

១.២.២ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង ....................................................... 11

២. បែបបទអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ គោលការណ៍ណែនាំស្ដីពីការប្រើប្រាស់ អវប សម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ........................................................................ 12

២.១ ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ ..........................................................................12

២.២ ប្រព័ន្ធក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ...........................................................13

២.២.១ ការទទួលបានក្រេឌីត និងម៉ោងអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ...............................13

២.២.២ ការផ្ដល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់.........................14

២.២.៣ ការផ្ដល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង ....................................15

២.៣ ទំនាក់ទំនង និងការបន្សើរវាងប្រព័ន្ធ អវប និងប្រព័ន្ធផ្សេងទៀត..................................17

២.៣.១ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធវាយតម្លៃ ............................................17

២.៣.២ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) និងប្រព័ន្ធគន្លងអាជីពគ្រូបង្រៀន..........................................................................................18

២.៣.៣ ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន............................18

២.៣.៤ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធប្រឹក្សាគរុកោសល្យ................................ 20

៣. គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងប្រព័ន្ធ អវប............................................................ 23

៣.១ កម្រិតទទួលខុសត្រូវ និងភារកិច្ច..........................................................................23

៣.១.១ សាលារៀន គណៈកម្មការ អវប កម្រងសាលារៀន និងសហគមន៍សិក្សាវិជ្ជាជីវៈ.............. 23

៣.១.២ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ .............................................24

៣.១.៣ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត.................................................... 25

៣.១.៤ ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធ HRMIS ........................... 25



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៣.១.៥ អ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ....26
៣.២ លំហូរព័ត៌មានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គន្លងអាជីពគ្រូបង្រៀន និង HRMIS....27
៤. បែបបទ និងយន្តការទទួលស្គាល់គុណភាពអ្នកផ្តល់សេវា និងសកម្មភាព អវប .... 32
៤.១ គ្រឹះស្ថាន និងដំណើរការ....32
៤.១.១ អង្គភាពដែលផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងសកម្មភាពអវប.... 32
៤.១.២ នីតិវិធីទទួលស្គាល់គុណភាព .... 32
៤.២ ការទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវា អវប....33
៤.៣ ការទទួលស្គាល់គុណភាពសកម្មភាព អវប ....34
៤.៤ ការអនុវត្តលក្ខណៈវិនិច្ឆ័យកំណត់គុណភាពអប្បបរមា....35
៥. ព័ត៌មាន និងការផ្សព្វផ្សាយដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ .... 35
៥.១ ការផ្សព្វផ្សាយអំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ....35
៥.២ ដំណើរការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមប្រព័ន្ធអនឡាញ....36
ឯកសារយោង.... 37
ឧបសម្ព័ន្ធ.... 38
១. ឧបករណ៍វាយតម្លៃតម្រូវការ អវប សម្រាប់គ្រូបង្រៀន ....38
២. ឧបករណ៍វាយតម្លៃតម្រូវការ អវប សម្រាប់នាយកសាលា ....40
៣. កម្រងស្នាដៃវិជ្ជាជីវៈ....43
៤. ទម្រង់គំរូនៃផែនការសិក្សាវិជ្ជាជីវៈ....47
៥. ទម្រង់គំរូកំណត់ត្រាអាជីព....51
៦. ទម្រង់គំរូនៃវិញ្ញាបនបត្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ....52
៧. ទម្រង់គំរូនៃប្រតិទិនប្រចាំឆ្នាំបង្ហាញពីសេវា ឬព្រឹត្តិការណ៍ អវប....53
៨. ឧបករណ៍សម្រាប់ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា និងសកម្មភាព អវប....55
៨.១ ពាក្យស្នើសុំការទទួលស្គាល់គុណភាពអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ .... 55
៨.២ ពាក្យស្នើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន.....59
៨.៣ ពាក្យស្នើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា 65
៨.៤ ពាក្យស្នើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលាគរុកោសល្យ ....71
៨.៥ ឧបករណ៍វាយតម្លៃសំណើសុំការទទួលស្គាល់គុណភាពអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ77

៨.៦ ឧបករណ៍វាយតម្លៃសំណើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន ..... 79
៨.៧ ឧបករណ៍វាយតម្លៃសំណើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលារៀន..... 83
៨.៨ ឧបករណ៍វាយតម្លៃសំណើសុំការទទួលស្គាល់គុណភាពសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលាគរុកោសល្យ..... 87
៩. ឧទាហរណ៍ដែលបង្ហាញពីការផ្តល់ក្រេឌីត អវប ..... 91
១០. សន្ទានុក្រម ..... 94
១១. តួនាទីរបស់ការិយាល័យគ្រប់គ្រង អវប ..... 96

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## បញ្ជីពាក្យកាត់ និងអក្សរកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ACC | Accreditation Committee of Cambodia | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| ASEAN | Association of South East Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AMS | ASEAN Member State | រដ្ឋជាសមាជិកអាស៊ាន |
| BA | Bachelor of Arts | បរិញ្ញាបត្រ |
| B Ed | Bachelor of Education | បរិញ្ញាបត្រអប់រំ |
| អវប | Continuous Professional Development | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (អវប) |
| អវបMO | Continuous Professional Development Management Office | ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| DoPers | Department of Personnel | នាយកដ្ឋានបុគ្គលិក |
| DoE | District Office of Education | ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ |
| DP | Development Partner | ដៃគូអភិវឌ្ឍន៍ |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| GPE 3 | General Partnership for Education phase 3 programme | កម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ ដំណាក់កាលទី៣ |
| HRMIS | Human Resources Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| ICT | Information and Communications Technologies | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |

| | | |
|---|---|---|
| INSET | In-Service Training | វិក្រឹតការគ្រូបង្រៀន |
| MA | Master of Arts | បរិញ្ញាបត្រជាន់ខ្ពស់ |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MOOC | Massive Open Online Course | វគ្គបណ្ដុះបណ្ដាលអនឡាញបើកទូលាយ |
| NGO | Non-Governmental Origanisation | អង្គការក្រៅរដ្ឋាភិបាល |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| NQF | National Qualifications Framework | ក្របខណ្ឌគុណវុឌ្ឍិជាតិ |
| OECD | Organisation for Economic Co-operation and Development | អង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច |
| PoE | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| PhD | Doctor of Philosophy ( Doctorate ) | បណ្ឌិត |
| PLC | Professional Learning Community | សហគមន៍សិក្សាវិជ្ជាជីវៈ |
| PLP | Professional Learning Plan | ផែនការសិក្សាវិជ្ជាជីវៈ |
| PTEC | Phnom Penh Teacher Education College | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| PTTC | Provincial Teacher Training Centre | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |
| QA | Quality Assurance | ការធានាគុណភាព |
| RTTC | Regional Teacher Training Centre | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| SBM | School-Based Management | ការគ្រប់គ្រងតាមសាលារៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| SEIP | Secondary Education Improvement Project | គម្រោងកែលម្អការអប់រំមធ្យមសិក្សា |
| STEPCam | Strengthening Teacher Education Programmes in Cambodia | កម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា |
| TCP | Teacher Career Pathways | គន្លងអាជីពគ្រូបង្រៀន |
| TD | Technical Department | នាយកដ្ឋានជំនាញ |
| TEI | Teacher Education Institution | គ្រឹះស្ថានអប់រំគ្រូបង្រៀន |
| TEPS | Teacher Education Provider Standards | ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន |
| TPAP | Teacher Policy Action Plan | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| TQU | Teacher Qualifications Upgrade | ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន |
| TVET | Technical and Vocational Education and Training | ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | United Nations Educational, Scientific and Cultural Organisation | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ |
| UNICEF | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USESDP-2 | Upper Secondary Education Sector Development Programme - 2 | គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី ២ |

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលបានចែងអំពីចក្ខុវិស័យដ៏មុតមាំ ក្នុងការផ្តល់ឱកាសដល់គ្រូបង្រៀន នាយកសាលា និងបុគ្គលិក អប់រំដទៃសម្រេចបាននូវសក្តានុពលវិជ្ជាជីវៈដ៏ពេញលេញ។ នេះជាការចូលរួមចំណែកសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្នុងការអភិវឌ្ឍមូលធនមនុស្សសម្រាប់បរិវត្តកម្មកម្ពុជាឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

ដើម្បីសម្រេចបានគោលដៅនេះ ទាមទារឱ្យពលរដ្ឋគ្រប់រូបមានសមត្ថភាពខ្ពស់ ការលើកទឹកចិត្ត និងការចូលរួមយ៉ាងសកម្មក្នុងការបន្តអភិវឌ្ឍជំនាញ និងចំណេះដឹងជាទៀងទាត់ តាមរយៈការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព។ បុគ្គលិកអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញលើកទឹកចិត្តដល់សិស្ស និស្សិតឱ្យក្លាយជាអ្នកសិក្សាពេញមួយជីវិត និងជាគំរូក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីទទួលយកចំណេះដឹង ជំនាញ ការចង់ដឹងចង់ឃើញ និងលើកទឹកចិត្តយុវជនកម្ពុជាឱ្យក្លាយជាពលរដ្ឋដែលយល់ដឹងច្បាស់ពីមហិច្ឆតាដ៏មុតមាំនេះ។

ផ្អែកលើគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ និងផែនការសកម្មភាពគ្រូបង្រៀនឆ្នាំ២០១៥ ក្របខណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា ត្រូវបានចងក្រងឡើងនៅឆ្នាំ២០១៩ ដែលជាផែនទីបង្ហាញផ្លូវដើម្បីអភិវឌ្ឍប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ហើយបានដាក់ចេញនូវចក្ខុវិស័យជំរុញការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គលិកអប់រំទាំងអស់។ ភ័ស្តុតាងស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអភិវឌ្ឍវិជ្ជាជីវៈមានប្រសិទ្ធភាពបំផុតនៅពេលអនុវត្តនៅសាលារៀន និងកន្លែងធ្វើការផ្ទាល់របស់បុគ្គលិកអប់រំ។ ការចាត់ទុកការបង្រៀនជាអាជីព និងការលើកទឹកចិត្តគ្រូបង្រៀនឱ្យអនុវត្តការងារប្រកបដោយទំនួលខុសត្រូវវិជ្ជាជីវៈ រួមទាំងការចូលរួមអភិវឌ្ឍវិជ្ជាជីវៈជាទៀងទាត់ ពិតជាមានសារៈសំខាន់ក្នុងការទាក់ទាញ និងរក្សាទុកបេក្ខជនល្អៗក្នុងអាជីពបង្រៀន ដែលអាចនាំ មកនូវការអប់រំប្រកបដោយគុណភាព។

ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានគោលបំណងប្រែក្លាយចក្ខុវិស័យនេះ ឱ្យទៅជាការពិតសម្រាប់បុគ្គលិកអប់រំគ្រប់រូប។ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនឹងអនុញ្ញាតឱ្យគ្រូបង្រៀន នាយកសាលា និងបុគ្គលិកអប់រំដទៃទៀតចូលរួមសកម្មភាពអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈផ្អែកលើចំណាប់អារម្មណ៍ និងតម្រូវការជាក់ស្តែង ព្រមទាំងទទួលបានក្រេឌីតដែលរួមចំណែកក្នុងការដំឡើងឋានៈវិជ្ជាជីវៈ និងគុណវុឌ្ឍិស្របតាមប្រព័ន្ធដំឡើងគុណវុឌ្ឍិបុគ្គលិកអប់រំជាតិ។

សៀវភៅណែនាំនេះត្រូវបានតាក់តែងឡើង ដើម្បីផ្តល់ការគាំទ្រដល់គ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ និងបុគ្គលិកអប់រំដទៃទៀតក្នុងការចូលរួមអភិវឌ្ឍវិជ្ជាជីវៈខ្លួនឯង និងគាំទ្រដល់ភាគីពាក់ព័ន្ធ ទាំងអស់ក្នុងការណែនាំ និងអនុវត្តប្រព័ន្ធនេះ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកពាក់ព័ន្ធដែល បានចូលរួមចំណែកក្នុងការអភិវឌ្ឍ និងអនុវត្តប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីផលប្រយោជន៍ដ៏សំខាន់របស់សិស្ស និស្សិត អ្នកសិក្សា និងប្រជាជនកម្ពុជា។ ខ្ញុំសង្ឃឹមថា សៀវភៅណែនាំនេះនឹងក្លាយជាឧបករណ៍ដ៏មានសារៈប្រយោជន៍ គាំទ្រដល់ការអនុវត្តប្រព័ន្ធ អវប សម្រាប់គ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ និងបុគ្គលិកអប់រំដទៃទៀតទូទាំងប្រទេស។

ថ្ងៃ ចន្ទ ១៣រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews
Chhouk Chanchhaya

## ១. សេចក្តីផ្តើម

សៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (អវប) នេះ ត្រូវបានតាក់តែងឡើងក្នុងគោលបំណង ផ្តល់ភាពងាយស្រួលដល់គ្រប់ភាគីពាក់ព័ន្ធដូចជា គ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ អ្នកគ្រប់គ្រង អ្នកផ្តល់សេវា អវប និងបុគ្គលិកអប់រំដទៃទៀត ក្នុងការរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើកំណែទម្រង់ដំណើរការកសាងសមត្ថភាពបុគ្គលិកអប់រំ រួមនឹងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ អវប ប្រកបដោយនវានុវត្តន៍។ ដូច្នេះ សៀវភៅណែនាំនេះ នឹងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីដំណើរការវិវឌ្ឍនៃប្រព័ន្ធ អវប។

### ១.១ គោលដៅរួមប្រព័ន្ធ អវប

#### និយមន័យ អវប

នៅក្នុងប្រទេសភាគច្រើន ការអប់រំគ្រូបង្រៀន គឺជាដំណើរការដែលធ្វើជាប់ជាប្រចាំ ពោលគឺចាប់ផ្តើមនៅពេលដែលគរុសិស្ស គរុនិស្សិតទទួលការបណ្តុះបណ្តាលដំបូង។ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ និងទទួលបានសញ្ញាបត្រគ្រូបង្រៀន គ្រូបង្រៀនត្រូវបន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនពេញមួយជីវិត។ បើទោះជាការផ្តល់អាជ្ញាប័ណ្ណឱ្យគ្រូបង្រៀននៅមិនទាន់អនុវត្តក្នុងប្រទេសកម្ពុជាក៏ដោយ នេះគឺជាយន្តការដែលចាំបាច់នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឈានទៅលើកកម្ពស់វិជ្ជាជីវៈបុគ្គលិកអប់រំ ក៏ដូចជាបង្កើនគុណភាពនៃការបង្រៀន។ នៅតាមប្រទេសជាច្រើន ការចូលរួម អវប ដែលធ្វើជាទៀងទាត់ប្រកបដោយគុណភាព គឺជាលក្ខខណ្ឌមួយ ដើម្បីឱ្យគ្រូបង្រៀនអាចទទួលបាន និងរក្សាអាជ្ញាប័ណ្ណបង្រៀនរបស់ខ្លួន។ គោលនយោបាយ អវប តម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំក្លាយទៅជាអ្នករៀនពេញមួយជីវិត។

នៅក្នុងក្របខណ្ឌ និងផែនការសកម្មភាពស្តីពី អវប បានឱ្យនិយមន័យថា "អវប គឺជាការបណ្តុះបណ្តាលឯកទេស ការអប់រំក្នុងប្រព័ន្ធនិងក្រៅផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ជាច្រើនប្រភេទ ដែលមានគោលបំណងជួយឱ្យគ្រូបង្រៀន នាយកសាលារៀន និងអ្នកឯកទេសអប់រំបង្កើនចំណេះដឹង និងជំនាញប្រកបដោយប្រសិទ្ធភាព" (ទំព័រទី៨)។ ការអភិវឌ្ឍវិជ្ជាជីវៈគួរតែ៖

- ធ្វើឡើងជាប្រចាំ
- ធ្វើស្វ័យភាព និងគ្រប់គ្រងការសិក្សាដោយខ្លួនឯង
- អនុវត្តផ្អែកតាមតម្រូវការ និងស្ថានភាពអភិវឌ្ឍន៍បច្ចុប្បន្នរបស់បុគ្គលម្នាក់ៗ
- កំណត់ពីលទ្ធផលការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈឱ្យបានច្បាស់លាស់ ដើម្បីបំពេញទៅតាមតម្រូវការរបស់បុគ្គល និងអង្គភាព
- វាយតម្លៃលទ្ធផលសិក្សាដោយផ្អែកលើសកម្មភាព និងភស្តុតាងជាក់លាក់
- ចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួន មិនមែនត្រឹមតែជាសកម្មភាពបន្ថែមដែលធ្វើក៏បាន មិនធ្វើក៏បាននោះឡើយ (Marchington & Wilkinson, 2009: 377)។

អវប ធ្វើឡើងតាមវិធីច្រើនយ៉ាងដូចជា សិក្ខាសាលា វគ្គបំប៉ន វគ្គបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ផ្សេងៗ កម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញ សហគមន៍សិក្សាវិជ្ជាជីវៈ និងសកម្មភាពដែលរៀនដោយខ្លួនឯង រួមមានការអានអត្ថបទស្រាវជ្រាវវិជ្ជាជីវៈ ការសង្កេតមើលការបំពេញការងាររបស់សហការី ការផ្តល់ប្រឹក្សាគរុកោសល្យ

និងការបង្វឹក ការស្រាវជ្រាវនៅក្នុងថ្នាក់រៀនឬការស្រាវជ្រាវប្រតិបត្តិ ការចូលរួមនៅក្នុងសន្និសីទឬសិក្ខាសាលា ការរក្សាទុកក្នុងទិនានុប្បវត្តិឬសៀវភៅកត់ត្រាពីអ្វីដែលបានរៀន ដើម្បីឆ្លុះបញ្ចាំងការអនុវត្តនៅក្នុងថ្នាក់រៀន ការអានអត្ថបទព័ត៌មាននានា ការស្ដាប់ podcasts ករណីសិក្សា និងព័ត៌មានថ្មីៗអំពីឧស្សាហកម្មអ្វីមួយ ការធ្វើទស្សនកិច្ចសិក្សាសង្កេតមើលបទពិសោធន៍នៅតាមសាលារៀនដទៃទៀត។ល។

សកម្មភាពដូចបានរៀបរាប់ខាងលើមានគោលដៅលើកកម្ពស់ចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួន ដែលផ្ដល់លទ្ធភាពឱ្យបន្តបង្កើនជំនាញ ស្របទៅតាមគោលដៅរបស់ស្ថាប័ន គោលដៅវិជ្ជាជីវៈ និងគោលដៅផ្ទាល់ខ្លួន។

ប្រព័ន្ធ អវប ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់វិជ្ជាជីវៈ និងគុណភាពរបស់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ព្រមទាំងបង្កើនគុណភាពនិងស្ដង់ដានៃការអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងគុណវុឌ្ឍិ។ ការចូលរួមនៅក្នុង អវប មិនប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សទេ។ ដូច្នេះ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ មិនត្រូវទុកការបង្រៀន និងកាតព្វកិច្ចវិជ្ជាជីវៈដទៃទៀតចោល ដើម្បីឆ្លៀតពេលទៅចូលរួមនៅក្នុងសកម្មភាព អវប នោះឡើយ។

គោលនយោបាយ អវប ចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀន ដោយកំណត់ឱ្យចូលរួមនៅក្នុងសកម្មភាព អវប ចំនួន ១០០ម៉ោងក្នុងមួយឆ្នាំ ប្រហែលជា ៣ម៉ោងក្នុងមួយសប្ដាហ៍។ គោលនយោបាយនេះផ្ដល់អនុសាសន៍ឱ្យគ្រូបង្រៀនចំណាយពេលមិនបង្រៀន ៥ថ្ងៃក្នុងមួយឆ្នាំ ស្មើនឹង ៤០ម៉ោង មានន័យថា ចាំបាច់ត្រូវចំណាយពេលផ្ទាល់ខ្លួន ៦០ម៉ោងទៀតសម្រាប់ចូលរួមនៅក្នុងសកម្មភាព អវប ទើបអាចបាន ១០០ម៉ោង។ នៅក្នុងការអនុវត្តជាក់ស្ដែង គ្រូបង្រៀនមានសិទ្ធិ និងលទ្ធភាព ចូលរួមនៅក្នុងសកម្មភាព អវប យ៉ាងហោចណាស់ ៣ម៉ោងក្នុងមួយសប្ដាហ៍ ដោយប្រើប្រាស់ម៉ោងបំពេញការងារ ។ ឧទាហរណ៍ គ្រូបង្រៀនបឋមសិក្សាមិនបង្រៀននៅថ្ងៃព្រហស្បតិ៍សប្ដាហ៍ទី៤ នៃខែនីមួយៗ ដែលជាថ្ងៃសម្រាប់ប្រជុំបច្ចេកទេស ប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ ជួយសិស្សរៀនយឺតជាដើម ហើយផ្ដល់ឱកាសឱ្យគ្រូបង្រៀនបឋមសិក្សាចូលរួមសកម្មភាព អវប រយៈពេល ៣ម៉ោងនៅក្នុងអំឡុងពេលនេះ។ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ បង្រៀន ១៨ម៉ោង និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិបង្រៀន ១៦ម៉ោង ដែលផ្ដល់លទ្ធភាពឱ្យពួកគេមានពេល ៣ម៉ោងក្នុងមួយសប្ដាហ៍ ដើម្បីចូលរួមនៅក្នុងសកម្មភាព អវប។ ក្នុងករណីគ្រូបង្រៀន បង្រៀនពីរវេន នៅតាមសាលារៀនដែលជួបប្រទះនឹងការខ្វះគ្រូបង្រៀន អាចប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាព អវប ។ បន្ថែមលើកាតព្វកិច្ចចូលរួម សកម្មភាពអវប ១០០ម៉ោងក្នុងមួយឆ្នាំ ដើម្បីទទួលបានក្រេឌីតបន្ថែម គ្រូបង្រៀនដែលមានបំណងចូលរួម សកម្មភាព អវប ត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលចុងសប្ដាហ៍ និងវិស្សមកាល។

## ១.២ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមសាលារៀន

កន្លងមកគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំបានធ្វើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈ ការចូលរួមវគ្គសិក្ខាសាលា ឬវគ្គវិក្រឹតការនៅទីតាំងដែលឆ្ងាយពីអង្គភាព ដោយពុំបានធ្វើឱ្យប្រសើរនូវការបំពេញការងារនៅក្នុងថ្នាក់រៀនឡើយ ព្រោះថាសិក្ខាសាលា និងវគ្គបំប៉នទាំងនេះពុំបានឆ្លើយតបចំពោះបញ្ហាប្រឈម ដែលគ្រូបង្រៀនម្នាក់ៗជួបប្រទះនៅក្នុងការបង្រៀនទៅតាមបរិបទជាក់ស្ដែង ដូច្នេះសកម្មភាពទាំងនេះផ្ដល់នូវផលតិចតួចប៉ុណ្ណោះ។ បច្ចុប្បន្ននេះ មានភស្តុតាងជាច្រើនបង្ហាញថា អវប ដែលធ្វើឡើងនៅតាមសាលារៀនមានប្រសិទ្ធភាព ដោយសារមានឱកាសអនុវត្ត និងឆ្លុះបញ្ចាំង ហើយផ្សារភ្ជាប់ទៅនឹងដំណើរការបង្រៀន និងរៀន។ អវប សម្រាប់គ្រូបង្រៀន "ត្រូវរៀបចំយ៉ាងណា ដើម្បីឱ្យគ្រូបង្រៀនអាចផ្សារភ្ជាប់ទំនាក់ទំនង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជាមួយនឹងបទពិសោធន៍ផ្ទាល់ខ្លួន និងផ្តល់ឱកាសឱ្យយកចំណេះដឹងដែលទទួលបានពី អវប ទៅសាកល្បង និងធ្វើការឆ្លុះបញ្ចាំងនៅតាមសាលារៀន។ អ្នកចូលរួមនៅក្នុងសកម្មភាព អវប ត្រូវយកទ្រឹស្តីដែលទទួលបានទៅប្រើប្រាស់ជាមួយនឹងសិស្សក្នុងបរិបទជាក់ស្តែង ដើម្បីឱ្យពួកគេយល់ខ្លឹមសារកាន់តែស៊ីជម្រៅ" (Gathumbi et al., 2013: 8)។ ដូចគ្នានេះដែរ អវប សម្រាប់នាយកសាលា អាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាពបំផុត លុះត្រាណាតែផ្តោតលើការងារ និងផ្តល់ឱកាសឆ្លុះបញ្ចាំងលើស្ថានភាពជាក់ស្តែងនៅក្នុងសាលារៀន រួចដោះស្រាយស្ថានភាពដែលនាយកសាលាជួបប្រទះនៅក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនប្រចាំថ្ងៃ។ អវប សម្រាប់អ្នកឯកទេសអប់រំ អាចធ្វើឡើងនៅក្នុងអង្គភាពសាមី ឬនៅកន្លែងធ្វើការមួយផ្សេងទៀត អាស្រ័យលើប្រធានបទ និងកន្លែងបំពេញការងារ។

បច្ចុប្បន្ន នៅក្នុងការអប់រំគ្រូបង្រៀន ព្រមទាំងការអនុវត្ត អវប បានបញ្ជាក់ពីតួនាទីនៃការឆ្លុះបញ្ចាំងនៅគ្រប់កម្រិតទាំងអស់ ដែលគ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ ឬគរុសិស្ស គរុនិស្សិត ត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំង និងត្រូវឆ្លុះបញ្ចាំងពីការអនុវត្ត ដោយផ្សារភ្ជាប់ទ្រឹស្តី បទពិសោធន៍ ទៅនឹងការអនុវត្តនៅក្នុងថ្នាក់រៀន ឬអង្គភាព ហើយត្រូវបន្តធ្វើបែបនេះឱ្យបានជាប់ជាប្រចាំ។

**ការអនុវត្ត អវប មាន ០២ទម្រង់៖**

- អវប មានរចនាសម្ព័ន្ធច្បាស់លាស់ សំដៅលើការសិក្សា វគ្គបំប៉ន វគ្គបណ្តុះបណ្តាលក្នុងប្រព័ន្ធ ឬសកម្មភាពដទៃទៀត ដែលផ្តល់ដោយអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន ដៃគូអភិវឌ្ឍន៍ និងនាយកដ្ឋានជំនាញក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការជាមួយគ្រឹះស្ថានអប់រំគ្រូបង្រៀន
- អវប រៀនដោយខ្លួនឯង សំដៅលើសកម្មភាពដែលបុគ្គលិកអប់រំធ្វើឡើងដោយខ្លួនឯង ដោយពុំមានការគាំទ្រជាផ្លូវការពីអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាព ប៉ុន្តែស្ថិតនៅក្នុងវិសាលភាពក្របខណ្ឌ អវប ដែរ។

ក្រេឌីត អវប អាចទទួលបានតាមរយៈការចូលរួមសកម្មភាព អវប ទាំងពីរទម្រង់។ ក្របខណ្ឌ និងផែនការសកម្មភាព អវប សម្រាប់គ្រូបង្រៀន និងនាយកសាលាឆ្នាំ២០១៩ លើកឡើងពីប្រព័ន្ធក្រេឌីត អវប "កូនកាត់" ដែលបញ្ជាក់ពីក្រេឌីត អវប សម្រាប់ការសិក្សាដំឡើងគុណវុឌ្ឍិ (Academic) និង ក្រេឌីត អវប សម្រាប់អាជីព (Non Academic) មិនប្រើសម្រាប់ការសិក្សាដំឡើងគុណវុឌ្ឍិទេ។ អវប ក្នុងទម្រង់ជាការសិក្សាដំឡើងគុណវុឌ្ឍិ សំដៅលើ អវប ដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬគ្រឹះស្ថានឧត្តមសិក្សា ដែលនាំឱ្យមានការផ្តល់ក្រេឌីតទៅតាមវគ្គសិក្សា ក្នុងក្របខណ្ឌដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ អវប មិនសម្រាប់ការសិក្សាដំឡើងគុណវុឌ្ឍិ អាចជាប្រភេទ អវប ដែលធ្វើនៅតាមសាលារៀន សាលាកម្រង ឬដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬក្រសួងអប់រំ យុវជន និងកីឡា។

### ១.២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់

អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ជាសកម្មភាព ដែលផ្តល់ដោយអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាព ហើយមានការកំណត់ច្បាស់លាស់នូវសកម្មភាពបណ្តុះបណ្តាលជួបផ្ទាល់។ សកម្មភាពដែលជួបផ្ទាល់អាចធ្វើឡើងជាទម្រង់សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន សកម្មភាពស្រាវជ្រាវជាក្រុម ឬសកម្មភាពដទៃទៀត។ អ្នកសិក្សាចូលរួមសកម្មភាពជួបផ្ទាល់មួយម៉ោង ត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ម៉ោងបន្ថែម។

អវប ជាដំណើរការដែលសកម្ម ដូច្នេះគ្រូបង្រៀនត្រូវមានតួនាទីសំខាន់ និងម្ចាស់ការក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ អវប មានចេតនាសម្ព័ន្ធច្បាស់លាស់ ក៏តម្រូវឱ្យមានការធ្វើស្វ័យសិក្សាក្នុងក្របខណ្ឌពេលវេលាមួយសមស្រប និងតម្រូវឱ្យគ្រូបង្រៀន ឬនាយកសាលាបង្ហាញថា ពិតជាបានចូលរួមនៅក្នុងដំណើរការ អវប ពិតប្រាកដមែន។ អ្នកចូលរួម អវប ត្រូវបញ្ជាក់ពីភស្តុតាងថាពិតជាបានយកមេរៀនដែលទទួលបាន ទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ក្នុងថ្នាក់រៀន ឬសាលារៀន ដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងនីតិវិធីដែលជួយឱ្យការបង្រៀន និងការដឹកនាំកាន់តែមានភាពល្អប្រសើរ។

### ១.២.២ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង

អវប រៀនដោយខ្លួនឯង ធ្វើឡើងផ្អែកទៅតាមប្រភពជាគុចូល និងលក្ខខណ្ឌតម្រូវដែលគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗស្វែងរកដោយខ្លួនឯង ដោយមិនប្រើប្រាស់សេវារបស់អ្នកផ្តល់សេវា អវប។ ប្រភពជាគុចូលទាំងនេះរួមមាន វគ្គបណ្តុះបណ្តាលអនឡាញបើកទូលាយ (MOOC) ការចូលរួមនិងការបង្ហាញស្នាដៃស្រាវជ្រាវផ្ទាល់ខ្លួននៅក្នុងសន្និសីទ ឬសកម្មភាពសិក្សាវិជ្ជាជីវៈដទៃទៀត ការចូលរួមនៅក្នុងការស្រាវជ្រាវ ការអានឯកសារស្រាវជ្រាវវិជ្ជាជីវៈក្នុងទម្រង់ជាព្រឹត្តិបត្រស្រាវជ្រាវឬសៀវភៅ ការស្រាវជ្រាវ និងបោះពុម្ពផ្សាយអត្ថបទអ្វីមួយជាដើម។ នៅពេលដែលប្រព័ន្ធផ្តល់ក្រេឌីត អវប រៀនដោយខ្លួនឯង ត្រូវបានដាក់ឱ្យដំណើរការ នោះការិយាល័យគ្រប់គ្រង អវប នឹងផ្សព្វផ្សាយបញ្ជីប្រភពជាគុចូលដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ការអនុវត្ត អវប រៀនដោយខ្លួនឯង ពីប្រភពមិនទាន់មានការទទួលស្គាល់គុណភាព ក៏អាចទទួលបានក្រេឌីតផងដែរ។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវដាក់សំណើសុំការទទួលស្គាល់គុណភាពទៅការិយាល័យគ្រប់គ្រង អវប លើប្រភពដែលខ្លួនបានសិក្សា។

ចំពោះការអនុវត្ត អវប រៀនដោយខ្លួនឯងពីប្រភពណាមួយ ក្នុងរយៈពេល ១ម៉ោង អ្នកចូលរួមត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ម៉ោងបន្ថែម។ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ត្រូវបង្ហាញពីការចូលរួមយ៉ាងសកម្មក្នុងដំណើរការ អវប តាមរយៈការផ្តល់ជាភស្តុតាងបញ្ជាក់ថា ពិតជាបានយកទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈនៅក្នុងថ្នាក់រៀន សាលារៀន និងត្រូវធ្វើការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងបង្ហាញពីរបៀបការសិក្សា ដែលជួយឱ្យការបំពេញការងារកាន់តែល្អប្រសើរជាងមុន។

ការអនុវត្តប្រព័ន្ធ អវប ធ្វើឡើងដោយប្រើប្រាស់អភិក្រមជាដំណាក់កាល ដោយសារតែមានការលំបាក និងភាពស្មុគស្មាញក្នុងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ អវប ដែលតម្រូវឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើននៃវប្បធម៌ និងការអនុវត្តការងារជាប្រចាំ។ នៅក្នុងដំណាក់កាលទី១ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ មានការផ្តោតការយកចិត្តទុកដាក់ជាចម្បងលើ អវប សម្រាប់គ្រូបង្រៀន និងនាយកសាលា។ អវប សម្រាប់អ្នកឯកទេសអប់រំ និងបុគ្គលិកអប់រំផ្សេងៗទៀត នឹងត្រូវបញ្ចូល ទៅក្នុងដំណាក់កាលទី២ ព្រមទាំងបន្តអភិវឌ្ឍប្រព័ន្ធ អវប សម្រាប់គ្រូបង្រៀន និងនាយកសាលាដូចជា ការដាក់ឱ្យអនុវត្តនូវ អវប រៀនដោយខ្លួនឯងជាដើម។ នេះតម្រូវឱ្យមានការកំណត់បុរេលក្ខខណ្ឌមួយចំនួនដូចជា ការអភិវឌ្ឍស្តង់ដារវិជ្ជាជីវៈសម្រាប់អ្នកឯកទេសអប់រំ ដែលបច្ចុប្បន្ននេះនៅមិនទាន់មាននៅឡើយ។ ការអនុវត្តអភិក្រមជាដំណាក់កាលបែបនេះ មិនគួររារាំងអ្នកឯកទេសអប់រំ និងបុគ្គលិកអប់រំផ្សេងៗទៀតមិនឱ្យចូលរួមក្នុងសកម្មភាព អវប មុនដំណាក់កាលទី២ នៃដំណើរការនេះឡើយ។ ការប្រើប្រាស់អភិក្រមបែបនេះគ្រាន់តែឆ្លុះបញ្ចាំងពីអាទិភាពរបស់ក្រសួង អយក តែប៉ុណ្ណោះ ក្នុងគោលបំណងធានាយ៉ាងណាឱ្យបុគ្គលិកអប់រំទាំងអស់ទទួលបាននូវចំណេះដឹង និងជំនាញវិជ្ជាជីវៈដែលចាំបាច់ សម្រាប់ការបំពេញការងារ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២. បែបបទអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ អវប សម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ

អវប គឺជាដំណើរការមួយដ៏សកម្ម ពេលការចូលរួមវគ្គ អវប តែម៉្យាងមិនធ្វើឱ្យល្អប្រសើរដល់ការបង្រៀន និងរៀនទេ កត្តាសំខាន់ត្រូវយកខ្លឹមសារដែលទទួលបានទៅប្រើប្រាស់នៅក្នុងការបង្រៀន និងរៀន ដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹង និងជំនាញ ហើយជួយឱ្យការបង្រៀនកាន់តែប្រសើរ និងកាន់តែឆ្លើយតបចំពោះតម្រូវការរបស់សិស្ស។ ការអនុវត្តបែបនេះក៏ត្រូវធ្វើឡើងសម្រាប់នាយកសាលា និងអ្នកឯកទេសអប់រំផងដែរ។ អវប សំដៅលើការអភិវឌ្ឍខ្លួនឯង និងតម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំប្រើប្រាស់ឱកាសដែលផ្តល់ឱ្យដើម្បីអភិវឌ្ឍជំនាញ និងចំណេះដឹងវិជ្ជាជីវៈ។ ការអនុវត្ត អវប មានសកម្មភាពជាច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ។ អ្នកអនុវត្ត អវប ត្រូវចូលរួមវាយតម្លៃលើតម្រូវការ និងរៀបចំផែនការអនុវត្ត អវប រៀងៗខ្លួន ដោយផ្អែកទៅតាមតម្រូវការបុគ្គល និងអង្គភាពហើយមានការគាំទ្រពីគណៈគ្រប់គ្រង។

### ២.១ ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ

គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗ ត្រូវមានផែនការសិក្សាវិជ្ជាជីវៈ។ នៅក្នុងបរិបទដទៃទៀតគេហៅផែនការសិក្សាវិជ្ជាជីវៈ ថាជាផែនការអភិវឌ្ឍវិជ្ជាជីវៈ។ នៅក្នុងផែនការនេះត្រូវមានសមាសភាពដូចជា៖

- ផ្នែកអនុវត្ត ឬចំណេះដឹងដែលត្រូវផ្តោតការយកចិត្តទុកដាក់ ដែលតម្រូវឱ្យមានការវាយតម្លៃលើតម្រូវការ អវប
- គោលបំណង ដែលរំពឹងថានឹងសម្រេចបាន
- ជំនាញសំខាន់ៗដែលចាំបាច់ដើម្បីសម្រេចគោលបំណងនីមួយៗ
- សកម្មភាព ឬវិធីសម្រេចគោលបំណង
- លក្ខណៈវិនិច្ឆ័យកំណត់ភាពជោគជ័យ
- ពេលវេលាធ្វើការវាយតម្លៃលើវឌ្ឍនភាពដែលសម្រេចបាន និងការបញ្ចប់សកម្មភាព។

ផែនការសិក្សាវិជ្ជាជីវៈ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ។ ក្នុងកិច្ចប្រជុំវាយតម្លៃទៀងទាត់ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ និងអ្នកគ្រប់គ្រង ធ្វើការពិភាក្សា និងឯកភាពគ្នាលើប្រធានបទមួយ ពីរ ឬច្រើនបំផុតបី ដើម្បីបញ្ចូលក្នុងផែនការសិក្សាវិជ្ជាជីវៈ។ ប្រធានបទទាំងនេះរួមមាន៖

- តម្រូវការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន
- ចំណាប់អារម្មណ៍ដែលចង់ធ្វើការអភិវឌ្ឍ
- សកម្មភាពចាំបាច់ត្រូវអភិវឌ្ឍ (សង្កេតការបង្រៀន ឬពេលចុះពិនិត្យតាមដាន)
- វិធី ឬទ្រឹស្តីនៃការធ្វើផែនការកែលម្អសាលារៀន។

សម្រាប់ប្រធានបទនីមួយៗដែលពាក់ព័ន្ធនឹងការអនុវត្តការងារ អាចមានសកម្មភាព អវប ច្រើនយ៉ាង។ គ្រូបង្រៀន នាយកសាលា និងអ្នកគ្រប់គ្រង ត្រូវកំណត់គោលដៅ និងលទ្ធផលរំពឹងទុកដោយមានការឯកភាពគ្នាលើសកម្មភាពអនុវត្ត និងធនធានដែលចាំបាច់។ សកម្មភាពទាំងនេះអាចមានដូចជា ការចុះឈ្មោះចូលរួមនៅក្នុងសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ណាមួយ មាននៅក្នុងបញ្ជីដែលផ្សព្វផ្សាយដោយការិយាល័យគ្រប់គ្រង អវប។

អ្នកធ្វើផែនការត្រូវមានការឯកភាពគ្នាលើលក្ខណៈវិនិច្ឆ័យជោគជ័យ ថាតើភាពជោគជ័យមានលក្ខណៈដូចម្ដេច ហើយធ្វើដូចម្ដេចឱ្យដឹងថា បានសម្រេចគោលដៅតាមផែនការ ព្រមទាំងកំណត់ពេលជាក់លាក់ណាមួយដើម្បីកំណត់វឌ្ឍនភាពដែលសម្រេចបាន។ ជាធម្មតាការវាយតម្លៃនេះ ត្រូវធ្វើឡើងនៅពាក់កណ្ដាលអាណត្តិ និងត្រូវមានកិច្ចប្រជុំវាយតម្លៃទៀងទាត់តាមអង្គភាព ឬគ្រឹះស្ថានសិក្សានៅចុងឆ្នាំសិក្សា ដែលជាពេលវាយតម្លៃជាផ្លូវការលើវឌ្ឍនភាពនៃការបំពេញការងារ។ សូមមើលទម្រង់គំរូផែនការសិក្សាវិជ្ជាជីវៈ និងឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធទី៤។

## ២.២ ប្រព័ន្ធក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ការផ្ដល់ក្រេឌីត អវប ត្រូវកំណត់តាម៖

- ចំនួនម៉ោងនៃសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ឬរៀនដោយខ្លួនឯងដោយជោគជ័យ
- ចំនួនម៉ោងស្វ័យសិក្សា ដែលមានទំនាក់ទំនងជាមួយនឹងចំនួនម៉ោង អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ឬរៀនដោយខ្លួនឯង
- គុណភាព ខ្លឹមសារនៃកម្មវិធី ឬសកម្មភាព អវប និងសមត្ថភាពដែលត្រូវបានលើកកម្ពស់ ដោយផ្អែកលើស្តង់ដាវិជ្ជាជីវៈ
- ការវាយតម្លៃផ្ដោតលើលទ្ធផលរំពឹងទុក និងផលជះ

សម្រាប់ព័ត៌មានលម្អិតអំពីប្រព័ន្ធក្រេឌីត អវប សូមមើលឯកសារស្ដីពីប្រព័ន្ធផ្ដល់ក្រេឌីត អវប ឆ្នាំ២០២១។

### ២.២.១ ការទទួលបានក្រេឌីត និងម៉ោងអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ចំនួនម៉ោង អវប តែមួយមុខ គឺមិនអាចចាត់ទុកថាជាមូលដ្ឋានសមស្របសម្រាប់ផ្ដល់ក្រេឌីត អវប ឡើយ។ ដើម្បីទទួលបានក្រេឌីត អវប សកម្មភាព អវប ចាំបាច់ត្រូវបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ ទាំងគុណភាព និងខ្លឹមសារ។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវបង្ហាញពីលទ្ធផលរំពឹងទុក និងផលជះតាមរយៈកិច្ចការវាយតម្លៃរបស់ខ្លួន។ លទ្ធផលនៃការចូលរួមអនុវត្ត អវប ត្រូវតែជាលទ្ធផលដែលអាចវាស់វែងបាន និងមានគុណភាពគ្រប់គ្រាន់ ទើបអាចទទួលបានក្រេឌីត។

គោលការណ៍មូលដ្ឋាននៃការផ្ដល់ក្រេឌីត អវប ចំនួន ១ក្រេឌីត តម្រូវឱ្យមានធាតុចូល ឬការចូលរួមសិក្សា បណ្ដុះបណ្ដាលផ្ទាល់ចំនួន ១៥ម៉ោងនិងស្វ័យសិក្សាចំនួន ៣០ម៉ោង ឬ៤៥ម៉ោង សម្រាប់ការងារចុះកម្មសិក្សា បូកជាមួយនឹងការសម្រេចបាននូវលទ្ធផលរំពឹងទុក ឬផលជះដែលអាចវាស់វែងបាន។

ការអនុវត្ត អវប រៀនដោយខ្លួនឯង គឺមិនគិតចំនួនម៉ោងរៀនផ្ទាល់ទេ ពោលគឺគិតទៅលើគុណភាព "ធាតុចូល" ដូចជា MOOC ឯកសារស្រាវជ្រាវវិជ្ជាជីវៈ ឬសៀវភៅសិក្សាជាដើម។ ដូច្នេះ អវប រៀនដោយខ្លួនឯងក៏មានការអនុវត្តគោលការណ៍ស្រដៀងគ្នានឹងគោលការណ៍ខាងលើដែរ ដោយសកម្មភាព អវប ដែលមានធាតុចូល ១៥ម៉ោង បានពីប្រភពដែលមានគុណភាពសមស្រប បូកនឹងស្វ័យសិក្សាឬការអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ឬការយកធាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងាររយៈពេល ៣០ម៉ោង ស្របតាមលក្ខណៈវិនិច្ឆ័យគុណភាព និងការសម្រេចលទ្ធផលរំពឹងទុក ឬផលជះ នឹងទទួលបានចំនួន ១ក្រេឌីត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**១ក្រេឌីត អវប នឹងត្រូវផ្តល់សម្រាប់៖**

- **ការសិក្សា ឬសកម្មភាពជួបផ្ទាល់រយៈពេល ១៥ម៉ោង + ៣០ម៉ោង ស្វ័យសិក្សា (ការងារអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ការពិសោធ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ)**
- **កម្មសិក្សាគរុកោសល្យ ឬការអនុវត្តផ្ទាល់រយៈពេល ៤៥ម៉ោង**
- **រៀនដោយខ្លួនឯងពីប្រភពមានគុណភាពសមស្រប ១៥ម៉ោង + ៣០ម៉ោង ស្វ័យសិក្សា (ការអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ការពិសោធ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ) ដោយមានការបញ្ជាក់លើលទ្ធផលសិក្សាពីគណៈគ្រប់គ្រងបានត្រឹមត្រូវ**
- **ស្វ័យសិក្សា ការពិសោធ ឬការងារចុះកម្មសិក្សារយៈពេល ៤៥ម៉ោង ដោយមានការបញ្ជាក់លើលទ្ធផលសិក្សាពីគណៈគ្រប់គ្រងបានត្រឹមត្រូវ**

**លទ្ធផលនៃការសិក្សាខាងលើត្រូវស្របតាមលក្ខណៈវិនិច្ឆ័យគុណភាព ឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុក និងផលជះដែលនាំឱ្យមានការផ្លាស់ប្តូរវិជ្ជមានក្នុងការអនុវត្តការងារ**

កិច្ចប្រជុំបច្ចេកទេសដែលពាក់ព័ន្ធនឹងការបំពេញការងារជាប្រចាំ ពុំទទួលបានក្រេឌីត អវប ទេ។ ប្រព័ន្ធក្រេឌីត អវប ត្រូវបានរៀបចំឡើងប្រកបដោយសង្គតិភាពជាមួយប្រព័ន្ធក្រេឌីតកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន។ ដើម្បីទទួលបានបរិញ្ញាបត្រអប់រំ គរុនិស្សិតចាំបាច់ត្រូវសន្សំឱ្យបានតិចបំផុត ១២០ក្រេឌីត ដែលត្រូវសម្រេចឱ្យបាន ១៥ក្រេឌីតក្នុងមួយឆមាស ក្នុងរយៈពេល ៤ឆ្នាំ។ វគ្គបណ្តុះបណ្តាលដែលមាន ៣ក្រេឌីត តម្រូវឱ្យគរុនិស្សិតចូលរួមស្តាប់បាឋកថារយៈពេល ៣ម៉ោង និងធ្វើស្វ័យសិក្សា ៦ម៉ោង ឬធ្វើការងារក្នុងមន្ទីរពិសោធន៍ ឬការងារចុះកម្មសិក្សា ៩ម៉ោង ជារៀងរាល់សប្តាហ៍ យ៉ាងហោចណាស់សម្រាប់រយៈពេល ១៥សប្តាហ៍ និងត្រូវបង្ហាញថា ពិតជាអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យវាយតម្លៃគុណភាពអប្បបរមា។ ដើម្បីបាន ៣ក្រេឌីត គរុនិស្សិតចាំបាច់ត្រូវសិក្សារយៈពេល ១៣៥ម៉ោង ដោយចូលរួមជាក់ស្តែង ៤៥ម៉ោង និងស្វ័យសិក្សា ៩០ម៉ោង។

### ២.២.២ ការផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់

នៅពេល អវប មានរចនាសម្ព័ន្ធច្បាស់លាស់ត្រូវបានអនុវត្តតាមរយៈអ្នកផ្តល់សេវា អវប ដែលទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន អ្នកផ្តល់សេវាត្រូវផ្តល់ឱ្យ អ្នកទទួលខុសត្រូវដែលពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ នូវព័ត៌មានការអនុវត្ត អវប ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) មានបញ្ជីឈ្មោះគ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ដែលបានអនុវត្តសកម្មភាព អវប ណាមួយ ដោយជោគជ័យដូចជា កាលបរិច្ឆេទ ទីកន្លែង ពិន្ទុ ឬក្រេឌីត ដែលទទួលបានជាដើម។ អង្គភាពពាក់ព័ន្ធដែលទទួលខុសត្រូវលើការបញ្ចូលទិន្នន័យទៅក្នុង HRMIS អាចជាសាលារៀន គ្រឹះស្ថានអប់រំគ្រូបង្រៀន ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប អាស្រ័យទៅតាមទីតាំង និងលទ្ធភាពមានអ៊ីនធឺណេតប្រើប្រាស់របស់សាលារៀន។ ការបញ្ចូលព័ត៌មានត្រូវធ្វើឡើងនៅកម្រិតថ្នាក់ក្រោមជាតិ ដែលអាចធ្វើទៅបាន ពោលគឺនៅកម្រិតសាលារៀន ឬកម្រិតគ្រឹះស្ថានអប់រំគ្រូបង្រៀន។ HRMIS មានផ្ទុកព័ត៌មានរួចទៅហើយអំពីអ្នកផ្តល់សេវា អវប និងសេវា អវប ដែលត្រូវបានទទួលស្គាល់គុណភាព ហើយដែលត្រូវបានវាយតម្លៃថាអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យគុណភាព និងលក្ខខណ្ឌ

នានា។ ព័ត៌មាននេះនឹងត្រូវបានបង្ហាញក្នុងម៉ូឌុល អវប នៃ HRMIS។ នៅពេលដែលឈ្មោះគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដែលបានចូលរួមប្រកបដោយជោគជ័យនៅក្នុងសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ត្រូវបានបញ្ចូលទៅក្នុង HRMIS ហើយព័ត៌មាននេះត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់នៅតាមលំដាប់ថ្នាក់ដែលពាក់ព័ន្ធ រួចចំនួនក្រេឌីត អវប នឹងបង្ហាញក្នុងកម្រងព័ត៌មានរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំម្នាក់ៗនៅក្នុង HRMIS (កំណត់ត្រាអាជីព)។ នៅពេលព័ត៌មានក្រេឌីត អវប ត្រូវបានបញ្ចូលទៅក្នុង HRMIS នៅកម្រិតសាលារៀន ឬគ្រឹះស្ថានអប់រំគ្រូបង្រៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អយក រាជធានី ខេត្ត ត្រូវផ្តល់ការធានាគុណភាពលើទិន្នន័យដែលបានបញ្ចូល និងត្រូវផ្ទៀងផ្ទាត់ទិន្នន័យ ព្រមទាំងត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើឯកសារនានា ដើម្បីបញ្ជាក់សុពលភាពព័ត៌មានដែលបញ្ចូលទៅក្នុងប្រព័ន្ធ។

បន្ទាប់ពីបានពិនិត្យទិន្នន័យគ្រប់ផ្នែកទាំងអស់នៃសកម្មភាព អវប និងកំណត់ត្រាអាជីពជាទម្រង់ឯកសារទន់ និងរឹង គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ត្រូវធ្វើបច្ចុប្បន្នភាព កំណត់ត្រាអាជីព ដោយមានការទទួលស្គាល់ពីការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយករាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប។ បុគ្គលម្នាក់ៗត្រូវរក្សាទុកកំណត់ត្រាអាជីពដោយខ្លួនឯង (សូមមើលឧបសម្ព័ន្ធទី៥ សម្រាប់ឧទាហរណ៍ស្តីពីសៀវភៅកត់ត្រា អវប ឬកំណត់ត្រាអាជីព)។

### ២.២.៣ ការផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង

គ្រូបង្រៀន និងគណៈគ្រប់គ្រងត្រូវព្រមព្រៀងគ្នាលើផែនការ និងសកម្មភាពសិក្សាវិជ្ជាជីវៈ ដែលរៀនដោយខ្លួនឯង នៅកម្រិតសាលារៀន កម្រងសាលារៀន ឬសហគមន៍សិក្សាវិជ្ជាជីវៈ។ ផែនការនេះត្រូវបានរៀបចំឡើងដោយមានបញ្ចូលចំនួនម៉ោងជាតុចូលបានពីប្រភព អវប រៀនដោយខ្លួនឯង ដែលត្រូវបានទទួលស្គាល់គុណភាពដូចជា វគ្គបណ្តុះបណ្តាល MOOC អត្ថបទដកស្រង់ចេញពីឯកសារស្រាវជ្រាវនិងជំពូកសៀវភៅដែលត្រូវអាន និងផែនការដែលកំណត់ពីស្វ័យសិក្សា ឬការអនុវត្តការឆ្លុះបញ្ចាំង បន្ទាប់មករៀបចំលទ្ធផលសិក្សាដើម្បីបង្ហាញពីផលជះនៃសកម្មភាព អវប រៀនដោយខ្លួនឯង។ នៅក្នុងអំឡុងពេលវាយតម្លៃទៀងទាត់តាមអង្គភាព ឬគ្រឹះស្ថានសិក្សា គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំត្រូវបង្ហាញពីកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន ដែលជាភស្តុតាងថា ពិតជាបានសម្រេចតាមផែនការសិក្សាវិជ្ជាជីវៈប្រកបដោយជោគជ័យ រួមនឹងភស្តុតាងពីលទ្ធផលរំពឹងទុក និងផលជះ។ ប្រសិនបើការវាយតម្លៃនេះទទួលបានលទ្ធផលវិជ្ជមាន អ្នកវាយតម្លៃត្រូវធ្វើការបញ្ជាក់ពីចំនួនក្រេឌីត អវប ដែលបានទទួល និងផ្សព្វផ្សាយព័ត៌មាននេះទៅកាន់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប ដែលត្រូវប្រមូលព័ត៌មាននេះ រក្សាទុកក្នុង HRMIS។ នៅពេលអនាគត HRMIS នឹងមានបញ្ចូលព័ត៌មានអំពីប្រភព អវប រៀនដោយខ្លួនឯង ដែលមានការទទួលស្គាល់គុណភាព និងចំពោះប្រភពដែលមិនទាន់មានការទទួលស្គាល់គុណភាព នឹងត្រូវវាយតម្លៃទៅតាមករណីជាក់ស្តែង។ ក្រោយពេលដែលព័ត៌មាននេះត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់នៅកម្រិតពាក់ព័ន្ធរួច ក្រេឌីត អវប នឹងបង្ហាញនៅក្នុងកម្រងព័ត៌មាន ឬកំណត់ត្រាអាជីពរបស់គ្រូបង្រៀនម្នាក់ៗ។

ក្រោយពីទទួលការវាយតម្លៃប្រកបដោយជោគជ័យរួចមក កំណត់ត្រាអាជីពរបស់បុគ្គលិកអប់រំម្នាក់ៗនឹងត្រូវធ្វើបច្ចុប្បន្នភាព ដោយមានការទទួលស្គាល់ផ្លូវការពីអង្គភាពសាមី។ បុគ្គលិកអប់រំម្នាក់ៗត្រូវរក្សា កំណត់ត្រាអាជីព ដោយខ្លួនឯង។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការិយាល័យគ្រប់គ្រង អវប មានតួនាទីគ្រប់គ្រង ម៉ូឌុល អវប នៅក្នុង HRMIS និងធានាឱ្យអ្នកអនុវត្ត អវប មានលទ្ធភាពចូលមើលទិន្នន័យរបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មានច្រកចំនួនពីរដើម្បីធ្វើការកត់ត្រាទិន្នន័យ អវប ទៅក្នុង HRMIS៖

1. **អ្នកផ្ដល់សេវា៖** អ្នកផ្ដល់សេវា អវប មានរចនាសម្ព័ន្ធច្បាស់លាស់ និងមានការទទួលស្គាល់គុណភាព ត្រូវកត់ត្រាក្រេឌីតរបស់អ្នកចូលរួមសកម្មភាព អវប និងបញ្ចូលបញ្ជីសកម្មភាព និងលទ្ធផល ទៅក្នុង HRMIS។ នេះគឺជាច្រកសម្រាប់ធ្វើការកត់ត្រាក្រេឌីតដែលអ្នកចូលរួមបានទទួល តាមរយៈការចូលរួមនៅក្នុងសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់
2. **សាលារៀន៖** សាលារៀន ឬគ្រឹះស្ថានសិក្សា ត្រូវវាយតម្លៃទៀងទាត់ លើការបញ្ចប់សកម្មភាព អវប ប្រកបដោយជោគជ័យ ធៀបនឹងផែនការសិក្សាវិជ្ជាជីវៈរបស់បុគ្គលិកអប់រំណាម្នាក់ ដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈ កត់ត្រាក្រេឌីតរបស់អ្នកចូលរួមសកម្មភាព អវប និងបញ្ចូលបញ្ជីសកម្មភាពនិងលទ្ធផល ទៅក្នុង HRMIS។ ក្នុងករណីដែលសាលារៀនពុំមានអ៊ីនធឺណេត ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ត្រូវមានតួនាទីបញ្ចូលទិន្នន័យទាំងនេះ។ នេះគឺជាច្រកសម្រាប់កត់ត្រាក្រេឌីត អវប ដែលទទួលបានពីការ ចូលរួម អវប រៀនដោយខ្លួនឯង។

ការិយាល័យគ្រប់គ្រង អវប ដែលស្ថិតនៅក្នុងនាយកដ្ឋានបុគ្គលិក នឹងចេញវិញ្ញាបនបត្រ អវប រៀងរាល់៥ឆ្នាំម្ដង ឬទៅតាមការចាំបាច់សម្រាប់ការឡើងឋានៈវិជ្ជាជីវៈ ដោយមានបញ្ជាក់ចំនួនក្រេឌីត អវប ដែលបុគ្គលិកអប់រំបានទទួល។ អ្នកផ្ដល់សេវា អវប ដែលមានការទទួលស្គាល់គុណភាព រាប់បញ្ចូលទាំងដៃគូអភិវឌ្ឍន៍អនុវត្តគម្រោងផងដែរ អាចប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ អវប ដោយខ្លួនឯងដូចជា ការកត់ត្រាវត្តមាន ការចូលរួម និងរបាយការណ៍លទ្ធផល ស្ដីពីសកម្មភាព អវប វិក្រឹតការ ការបណ្ដុះបណ្ដាល និងរបាយការណ៍ឆ្លុះបញ្ចាំងពីការយកខ្លឹមសារមេរៀនទៅអនុវត្តជាក់ស្ដែង រួចកំណត់ជាចំនួនក្រេឌីត អវប ដើម្បីបញ្ចូលទៅក្នុងម៉ូឌុល អវប នៃ HRMIS ។ ការផ្ដល់ក្រេឌីតត្រូវធ្វើឡើង តាមរយៈការិយាល័យគ្រប់គ្រង អវប ដែលជាលេខាធិការដ្ឋាន ទទួលស្គាល់គុណភាព និងផ្ដល់ក្រេឌីតផ្អែកតាមប្រព័ន្ធផ្ដល់ក្រេឌីត អវប។ កំណត់ត្រាអាជីពដែលរក្សាទុកដោយគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗ នឹងត្រូវយកមកប្រើប្រាស់នៅក្នុងគ្រប់ករណីទាំងអស់ ដើម្បីកត់ត្រាសកម្មភាព អវប និងក្រេឌីតដែលទទួលបាន។ ព័ត៌មានទាំងនេះនឹងត្រូវកត់ត្រាទៅក្នុងម៉ូឌុល អវប នៃ HRMIS ផងដែរ។

ចាប់ពីឆ្នាំ២០២១ ប្រព័ន្ធផ្ដល់ និងរក្សាទុកក្រេឌីត អវប នឹងត្រូវអនុវត្តជាដំណាក់ៗ ផ្ដើមពីក្រេឌីត អវប មានរចនាសម្ព័ន្ធច្បាស់លាស់។ ការអនុវត្តសកម្មភាព អវប នឹងពង្រីកវិសាលភាពបន្ថែមទៀត ដើម្បីបញ្ចូលលទ្ធផល អវប រៀនដោយខ្លួនឯងនៅឆ្នាំ២០២៥។ ដំបូង នឹងមានការផ្ដល់ក្រេឌីត អវប ដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដែលចូលរួមនៅក្នុងសកម្មភាព អវប មួយចំនួន ផ្ដល់ដោយអ្នកផ្ដល់សេវា អវប មានការទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលកំពុងអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (TQU) នាពេលបច្ចុប្បន្នដូចជា វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលផ្ដល់វគ្គបណ្ដុះបណ្ដាល និងវិក្រឹតការរួមមានគម្រោង STEPCam, SEIP, SBM និង USESDP-2 ជាដើម។ ការិយាល័យគ្រប់គ្រង អវប នឹងពិចារណាក្នុងការផ្ដល់ក្រេឌីតទៅលើសកម្មភាព អវប ដែលបាន និងកំពុងធ្វើនាពេលបច្ចុប្បន្ននេះផ្អែកលើភស្តុតាងជាក់ស្ដែង ។

## ២.៣ ទំនាក់ទំនង និងការបន្សុីវទាងប្រព័ន្ធ អវប និងប្រព័ន្ធផ្សេងទៀត

ប្រព័ន្ធ អវប មានទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សេងទៀតដូចជា ប្រព័ន្ធវាយតម្លៃតាមវដ្តទៀងទាត់ ប្រព័ន្ធវាយតម្លៃគន្លងអាជីពគ្រូបង្រៀន ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន និងប្រព័ន្ធដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ជាដើម។

### ២.៣.១ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធវាយតម្លៃ

ក្របខណ្ឌអនុវត្តគន្លងអាជីពគ្រូបង្រៀនជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំទាំងអស់ ត្រូវឆ្លងកាត់ការវាយតម្លៃដើម្បីកំណត់ និងផ្តល់លាភការដល់អ្នកដែលធ្វើបានល្អនៅក្នុងការងារដឹកនាំក៏ដូចជាការងារបង្រៀន ការចូលជាសមាជិកក្នុងក្រុមបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាដើម។ ការវាយតម្លៃត្រូវរកឱ្យឃើញ និងទទួលស្គាល់នូវចំណុចខ្វះខាតដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលការងារ។ ការវាយតម្លៃផ្តោតលើសមត្ថភាពវិជ្ជាជីវៈ ដូចដែលបានកំណត់នៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីសម្រេចឱ្យបានគោលដៅ អវប។ អ្នកដែលទទួលបានលទ្ធផលល្អ មានឱកាសឡើងឋានៈវិជ្ជាជីវៈទៅកម្រិតខ្ពស់បន្ទាប់ក្នុងគន្លងអាជីព។ ឯកសារ *ក្របខណ្ឌ និងសៀវភៅណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន* ផ្តល់ការពន្យល់លម្អិតអំពីប្រព័ន្ធវាយតម្លៃ និងរបៀបដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យនីមួយៗ។

ដូច្នេះ ក្រេឌីត អវប រួមចំណែកដល់លទ្ធផលនៃការវាយតម្លៃគន្លងអាជីពគ្រូបង្រៀន (សូមមើលរូបភាពទី១ ខាងក្រោម)។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

### ២.៣.២ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) និងប្រព័ន្ធគន្លងអាជីពគ្រូបង្រៀន

*រូបភាពទី ១៖ ទំនាក់ទំនងរវាងប្រព័ន្ធ អវប HRMIS និង គន្លងអាជីពគ្រូបង្រៀន*




### ២.៣.៣ ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

ប្រទេសកម្ពុជាបានប្តេជ្ញាឱ្យគ្រូបង្រៀនទាំងអស់មានគុណវុឌ្ឍិយ៉ាងហោចណាស់កម្រិតបរិញ្ញាបត្រអប់រំ ឬ ១២+៤។ បច្ចុប្បន្ននេះមានការអនុវត្តកម្មវិធីជាតិ ដើម្បីជួយឱ្យគ្រូបង្រៀនដែលមានគុណវុឌ្ឍិ ១២+២ អាចបង្កើនសមត្ថភាពរបស់ខ្លួនដល់កម្រិតបរិញ្ញាបត្រអប់រំ តាមរយៈវគ្គដំឡើងគុណវុឌ្ឍិនៅវិទ្យាស្ថានជាតិអប់រំសម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ វគ្គដំឡើងគុណវុឌ្ឍិនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ និងវគ្គដំឡើងគុណវុឌ្ឍិនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញសម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ ក្រេឌីត អវប ក៏អាចរួមចំណែកដល់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនផងដែរ។ តម្លៃ ១ក្រេឌីត ស្មើនឹងការរៀន ១ម៉ោងក្នុងមួយសប្តាហ៍ ដែលមានរយៈពេលយ៉ាងហោចណាស់ ១៥សប្តាហ៍ក្នុង១ឆមាស។ សម្រាប់ការរៀន ១ម៉ោង ត្រូវមានការធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ម៉ោង ហើយបរិមាណស្វ័យសិក្សាកើនឡើងទៅតាមកម្រិតគុណវុឌ្ឍិវគ្គសិក្សា។ វិធីដែលត្រូវបានប្រើប្រាស់សម្រាប់បំប្លែងម៉ោងរៀនទៅជាក្រេឌីត ក៏ត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនផងដែរ។

ដើម្បីបញ្ចប់កម្មវិធីអប់រំគ្រូបង្រៀនប្រកបដោយជោគជ័យ និងទទួលបានបរិញ្ញាបត្រអប់រំ គរុនិស្សិតត្រូវសិក្សាយ៉ាងតិច ១២០ក្រេឌីត ដោយត្រូវបែងចែកក្រេឌីតទាំងនេះទៅតាមមុខវិជ្ជាសិក្សាដូចខាងក្រោម៖

១. ការសិក្សាពីការអប់រំ
២. ចំណេះដឹងមុខវិជ្ជាឯកទេស (មត្តេយ្យសិក្សា និងបឋមសិក្សា) ខ្លឹមសារមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន (មធ្យមសិក្សាបឋមភូមិ)
៣.ការសិក្សាពីកម្មវិធីសិក្សា (វិធីសាស្ត្របង្រៀនដែលផ្សារភ្ជាប់ជាមួយនឹងមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន)
៤. ការលើកកម្ពស់ផ្នែកភាសាបរទេស (ការសរសេរសម្រាប់គោលបំណងសិក្សា ការអាន ការធ្វើបទបង្ហាញ) ជាភាសាបរទេស (អង់គ្លេស ឬបារាំង)
៥. ការស្រាវជ្រាវអប់រំ (ទ្រឹស្តី និងការអនុវត្តការស្រាវជ្រាវសម្រាប់ការសិក្សា)
៦. កម្មសិក្សាគរុកោសល្យ (ការអនុវត្តការបង្រៀន)
៧. វគ្គសិក្សាដែលសំខាន់ និងចាំបាច់ (ប្រធានបទ ឬខ្លឹមសារពាក់ព័ន្ធនឹងការបង្រៀន)

យោងតាមប្រកាស១៨៧០ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបានកំណត់ឱ្យរៀនត្រឹម ៦០ក្រេឌីត លើចំនួន ១២០ក្រេឌីត ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រអប់រំ ចំពោះអ្នកសិក្សាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានគុណវុឌ្ឍិ ១២+២
- មានបទពិសោធន៍ធ្វើជាគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា រយៈពេល ៥ឆ្នាំ
- មានអាយុមិនច្រើនជាង ៥៥ឆ្នាំនៅពេលដាក់ពាក្យ
- ឆ្លងកាត់ការប្រឡងជ្រើសរើសជាប់

ដូច្នេះ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនត្រូវការ ការសិក្សាពេញម៉ោងរយៈពេល ២ឆ្នាំ ឬការចូលរួមក្នុងវគ្គសិក្សានៅពេលវិស្សមកាលរយៈពេល ២ឆ្នាំ ស្មើនឹង ៥០ម៉ោង ក្នុងមួយសប្តាហ៍ រយៈពេល ៩សប្តាហ៍ (សរុបប្រមាណ ៩០០ម៉ោង សម្រាប់ការរៀនផ្ទាល់)។

កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដែលបានចាត់ចូលក្នុងសកម្មភាព អវប បានកំណត់ត្រឹម ៦០ក្រេឌីត សម្រាប់សិក្សាដល់កម្រិតបរិញ្ញាបត្រ។ ប៉ុន្តែការកំណត់ភាគរយលើក្រេឌីត អវប សម្រាប់មុខវិជ្ជាសិក្សានីមួយៗផ្សេងៗគ្នា និងទៅតាមប្រភេទគ្រូបង្រៀន ឧទាហរណ៍ សម្រាប់គ្រូបង្រៀនបឋមសិក្សាដែលមានសញ្ញាបត្របរិញ្ញាបត្រផ្នែកការបង្រៀន ឬបរិញ្ញាបត្រអប់រំបឋមសិក្សា ការចូលរួមនៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនអាចឱ្យពួកគេទទួលបាន ២ឬ៣ក្រេឌីតក្នុងចំណោម ៦ក្រេឌីត។ ការទទួលបានក្រេឌីតពី អវប ដរាបណាសកម្មភាព អវប ដែលផ្តល់ឱ្យត្រូវបានទទួលស្គាល់ថាជា "ការសិក្សាអំពីការអប់រំ"។ ក្នុងតារាងទី១ ខាងក្រោមមុខវិជ្ជាសិក្សានីមួយៗក្នុងចំណោមមុខវិជ្ជាសិក្សាទាំង៧ ត្រូវបានកំណត់ភាគរយនៃក្រេឌីតដែលផ្តល់ដោយ អវប ខុសៗគ្នាគឺ ១០០% សម្រាប់មុខវិជ្ជាជម្រើស ១០០% សម្រាប់មុខវិជ្ជាភាសាបរទេស និងបំណិនសិក្សា ហើយចន្លោះពី៣៣% ទៅ ៥០% សម្រាប់មុខវិជ្ជាសិក្សាផ្សេងទៀត។ សូមមើលតារាងទី១ ខាងក្រោមសម្រាប់ព័ត៌មានលម្អិតអំពីលក្ខខណ្ឌទៅតាមមុខវិជ្ជាសិក្សានីមួយៗ សម្រាប់គ្រូបង្រៀនប្រភេទផ្សេងៗគ្នា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ២.៣.៤ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធប្រឹក្សាគរុកោសល្យ

បច្ចុប្បន្ននេះ មានប្រព័ន្ធផ្ដល់ប្រឹក្សាគរុកោសល្យជាច្រើនសម្រាប់គ្រូបង្រៀន ដែលក្នុងនោះ គ្រូបង្រៀនទទួលបានការគាំទ្រអំពីរបៀបធ្វើឱ្យការបង្រៀនក្នុងថ្នាក់កាន់តែប្រសើរ តាមរយៈការជួបពិភាក្សាជាប្រចាំជាមួយនឹងអ្នកផ្ដល់ប្រឹក្សាគរុកោសល្យ។ ការទទួលបានប្រយោជន៍ពីការប្រឹក្សាគរុកោសល្យ សូម្បីតែនៅក្នុងប្រព័ន្ធផ្ដល់ប្រឹក្សាគរុកោសល្យដែលត្រូវបានទទួលស្គាល់គុណភាពក៏ដោយ ត្រូវបានគេចាត់ទុកថាជា អវប ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។ គ្រូបង្រៀនអាចទទួលបានក្រេឌីត អវប តាមរយៈការចូលរួមនៅក្នុងកម្មវិធីផ្ដល់ប្រឹក្សាគរុកោសល្យប្រកបដោយជោគជ័យ និងបង្ហាញថាការអនុវត្តនៅក្នុងថ្នាក់រៀនពិតជាបានប្រសើរជាងមុន បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីផ្ដល់ប្រឹក្សាគរុកោសល្យ ដោយត្រូវបង្ហាញនូវភស្តុតាងដែលអាចវាស់វែងបាន។ ការផ្ដល់ក្រេឌីត អវប ត្រូវបានធ្វើឡើង ដោយប្រើប្រាស់រូបមន្តដែលកំណត់នៅក្នុងផ្នែក២.២ ខាងលើ ដូចជា កម្មវិធីផ្ដល់ប្រឹក្សាគរុកោសល្យដែលត្រូវបានទទួលស្គាល់គុណភាពនីមួយៗ អាចឱ្យគេទទួលបានក្រេឌីត អវប ក្នុងចំនួនមួយដែលបានកំណត់។ គ្រូបង្រៀនដែលទទួលបានការគាំទ្រការប្រឹក្សាគរុកោសល្យ និងគ្រូបង្រៀន ឬអ្នកគ្រប់គ្រងដែលផ្ដល់ការប្រឹក្សាគរុកោសល្យ សុទ្ធតែអាចទទួលបានក្រេឌីត អវប ទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងប្រព័ន្ធក្រេឌីត អវប។ ជាតុចូលដែលមានរចនាសម្ព័ន្ធច្បាស់លាស់ផ្ដល់ដល់គ្រូបង្រៀនដែលទទួលបានការផ្ដល់ប្រឹក្សាគរុកោលស្យមានដូចជា ការអានឯកសារយោងស្ដីពីគរុកោសល្យ ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈដែលមានការកត់ត្រាត្រឹមត្រូវ និងការប្រើប្រាស់វិធីបង្រៀនថ្មីៗនៅក្នុងថ្នាក់រៀនក្រោមការសង្កេតមើលរបស់អ្នកផ្ដល់ប្រឹក្សាគរុកោសល្យដែលក្រោយមកត្រូវផ្ដល់ការគាំទ្រ ដើម្បីកំណត់ពីចំណុចដែលត្រូវធ្វើការកែលម្អបន្ថែម និងយុទ្ធសាស្ត្រដែលត្រូវប្រើប្រាស់ ដើម្បីសម្រេចការកែលម្អនេះ។ បន្ទាប់មកគ្រូបង្រៀនដែលទទួលបានការផ្ដល់ប្រឹក្សាគរុកោសល្យត្រូវអនុវត្តសកម្មភាពស្វ័យសិក្សាដូចជា អានឯកសារបន្ថែម និងត្រូវសរសេរកំណត់ត្រាឆ្លុះបញ្ចាំងឬរបាយការណ៍ បង្ហាញឱ្យឃើញពីរបៀបដោះស្រាយបញ្ហា និងបង្ហាញពីអ្វីដែលបានរៀនពីបទពិសោធន៍នេះ។ សៀវភៅកត់ត្រាអំណាន (reading log) កំណត់ត្រាការផ្ដល់ប្រឹក្សាគរុកោសល្យ និងរបាយការណ៍វឌ្ឍនភាព ដែលអាចបញ្ចូលទៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈ នឹងត្រូវបញ្ជាក់ផ្ទៀងផ្ទាត់នៅពេលវាយតម្លៃតាមវដ្តទៀងទាត់ (សូមមើលឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធទី៣)។

អ្នកផ្ដល់ប្រឹក្សាគរុកោសល្យអាចទទួលបានជាតុចូលដែលមានរចនាសម្ព័ន្ធច្បាស់លាស់ដូចជា តាមរយៈការចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលសម្រាប់អ្នកផ្ដល់ប្រឹក្សាគរុកោសល្យ ដែលធ្វើឡើងនៅកម្រិតកម្រងសាលារៀន ការអានឯកសារគរុកោសល្យ ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈដែលមានការកត់ត្រាត្រឹមត្រូវ ឬការផ្ដល់ការគាំទ្រដល់អ្នកដែលត្រូវទទួលការប្រឹក្សាគរុកោសល្យ ដើម្បីជួយកំណត់ពីផ្នែកដែលត្រូវធ្វើការកែលម្អ និងយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវការកែលម្អនេះ។ អ្នកផ្ដល់ប្រឹក្សាគរុកោសល្យក៏ចាំបាច់ត្រូវបង្ហាញឱ្យឃើញពីលទ្ធផលរំពឹងទុក និងផលជះ ចេញពីការផ្ដល់ប្រឹក្សាគរុកោសល្យដូចជា តាមរយៈការសរសេរកំណត់ត្រាឆ្លុះបញ្ចាំង និងរបាយការណ៍បង្ហាញពីយុទ្ធសាស្ត្រដែលបានប្រើប្រាស់ ដើម្បីជួយឱ្យគ្រូបង្រៀនឆ្លើយតបចំពោះបញ្ហាប្រឈមនៅក្នុងការបង្រៀន និងការដាក់ចេញនូវជំហានបន្ទាប់សម្រាប់អ្នកទទួលប្រឹក្សាគរុកោសល្យ និងអ្នកផ្ដល់ប្រឹក្សាគរុកោសល្យ។ ខណៈអ្នកផ្ដល់ប្រឹក្សាគរុកោសល្យយកមេរៀនទាំងនេះទៅប្រើប្រាស់ ត្រូវមានការពិនិត្យវាយតម្លៃ ដោយអ្នកផ្ដល់ប្រឹក្សាគរុកោសល្យដែលមានបទពិសោធន៍ (Master Mentor) ក្នុងកិច្ចប្រជុំវាយតម្លៃតាមវដ្តទៀងទាត់។ រាល់សកម្មភាពទាំងអស់នឹងត្រូវធ្វើការគណនាជាចំនួនម៉ោងស្របតាមរូបមន្តដែលប្រើប្រាស់សម្រាប់ផ្ដល់ក្រេឌីត អវប។

*តារាងទី១៖ ចំនួនក្រេឌីតសម្រាប់មុខវិជ្ជាសិក្សានៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដើម្បីទទួលបានបរិញ្ញាបត្រអប់រំផ្នែកការបង្រៀន និងចំនួនក្រេឌីត អវប សម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបង្ហាញនៅក្នុងវង់ក្រចក (ប្រកាសលេខ១៨៧០ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៩)*

| | មុខវិជ្ជាសិក្សា | គ្រូមត្តេយ្យសិក្សា (ពេញសិទ្ធិ) **គំរូ គ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀន ឬបរិញ្ញាបត្រមិនមែនជំនាញអប់រំកុមារតូច (TQU) **គំរូ ក** | គ្រូបឋមសិក្សា **គំរូ គ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀន ឬបរិញ្ញាបត្រមិនជំនាញអប់រំបឋមសិក្សា (TQU) **គំរូ ក** | គ្រូមធ្យមសិក្សាបឋមភូមិ **គំរូ គ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្រត្រូវមុខវិទ្យាឯកទេស (TQU) **គំរូ ខ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្ររងក្នុងការបង្រៀន ឬបរិញ្ញាបត្រមិនចំឯកទេសមុខវិជ្ជាដើម (TQU) **គំរូ ក** |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ការសិក្សាពីការអប់រំ | ១២ | ៤ (២) | ៦ (៣) | ១២ | ៤ (២) | ៦ (៣) | ១៥ | ៤ (២) | ៦ (៣) |
| ២ | ចំណេះដឹងមុខវិជ្ជាឯកទេស | ២៥ | ៩ (៤) | ៦ (៣) | ២៥ | ៩ (៤) | ១៤ (៥) | ៥៥ | ៩ (៤) | ២២ (៨) |
| ៣ | ការសិក្សាពីកម្មវិធីសិក្សា | ៥៤ | ០ (០) | ២៤ (១២) | ៥៤ | ០ (០) | ២១ (៧) | ១២ | ០ (០) | ៩ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | ការលើកកម្ពស់ផ្នែកភាសាបរទេស | ២ | ០ (០) | ២ (២) | ២ | ០ (០) | ២ (២) | ៨ | ០ (០) | ៦ (៦) |
| ៥ | ការស្រាវជ្រាវអប់រំ | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) |
| ៦ | កម្មសិក្សាគរុកោសល្យ | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) |
| ៧ | មុខវិជ្ជារួម (ចាំបាច់ និងសំខាន់) | ៤ | ២ (១) | ៤ (២) | ៤ | ២ (២) | ៤ (២) | ៧ | ២ (១) | ៤ (២) |
| | មុខវិជ្ជាជម្រើស | ០ | ១២ (១២) | ១៥ (១៥) | ០ | ១២ (១២) | ១០ (១០) | ០ | ១២ (១២) | ១០ (១០) |
| | សរុប | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) |

កម្រិតអតិបរមានៃចំនួនក្រេឌីត អវប ដែលត្រូវបានលើកស្នើឡើង បានបង្ហាញនៅក្នុងវង់ក្រចក ផ្អែកទៅតាមរូបមន្ត ១០០% សម្រាប់មុខវិជ្ជាភាសាបរទេស និងបំណិនសិក្សា និងមុខវិជ្ជាជម្រើស និងចន្លោះពី ៣៣% - ៥០% សម្រាប់មុខវិជ្ជាសិក្សាដទៃទៀត។ ចំនួនក្រេឌីត អវប អតិបរមាសម្រាប់ជួយដល់ការដំឡើងគុណវុឌ្ឍិមានចំនួនសរុប ៥០%។

## ៣. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងប្រព័ន្ធ អវប

### ៣.១ កម្រិតទទួលខុសត្រូវ និងភារកិច្ច

ផ្នែកនេះបង្ហាញពីការទទួលខុសត្រូវ និងភារកិច្ចនៃកម្រិតនីមួយៗរបស់ប្រព័ន្ធ អវប ដែលមានសង្ខេបនៅក្នុងតារាងទី២ ខាងក្រោម។

#### ៣.១.១ សាលារៀន គណៈកម្មការ អវប កម្រងសាលារៀន និងសហគមន៍សិក្សាវិជ្ជាជីវៈ

អវប សម្រាប់គ្រូបង្រៀន និងនាយកសាលាត្រូវគ្រោងរៀបចំ និងសម្របសម្រួលនៅកម្រិតសាលារៀន ហើយសាលារៀននីមួយៗត្រូវមានគណៈកម្មការ អវប។ គណៈកម្មការ អវប គឺជាអនុក្រុមរបស់គណៈកម្មាការគ្រប់គ្រងសាលារៀន ដែលមាននាយកសាលាជាប្រធាន មានសមាសភាពប្រធានក្រុមបច្ចេកទេសដែលបំពេញតួនាទីជាអ្នកសម្របសម្រួល និងគ្រូបង្រៀនមានបទពិសោធន៍ម្នាក់ទៀតទទួលខុសត្រូវផ្តល់ការប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនដទៃទៀត។

គណៈកម្មការនេះទទួលខុសត្រូវលើការរៀបចំ និងគ្រប់គ្រងចាត់ចែងសកម្មភាព អវប នៅក្នុងសាលារៀន៖

- កំណត់ និងវិភាគលើតម្រូវការ អវប
- ធ្វើផែនការ គ្រប់គ្រង និងសម្របសម្រួលសកម្មភាព អវប
- ផ្សព្វផ្សាយបញ្ជី និងចុះឈ្មោះគ្រូបង្រៀនចូលរួមក្នុងសកម្មភាព អវប
- ជួយគ្រូបង្រៀនក្នុងការអភិវឌ្ឍកម្រងស្នាដៃវិជ្ជាជីវៈ ដែលបង្ហាញពីសមិទ្ធផល អវប និងការឆ្លុះបញ្ចាំង
- ជួយគ្រូបង្រៀនក្នុងការរក្សាកំណត់ត្រាអាជីព
- សម្របសម្រួលការវាយតម្លៃគ្រូបង្រៀនដូចជា រៀបចំផែនការសិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗ និងវាយតម្លៃថាតើគ្រូបង្រៀនបានសម្រេចតាមគោលដៅ អវប របស់ខ្លួនកម្រិតណា
- សម្របសម្រួលការដឹកនាំការងារបង្រៀនដូចជាការបង្វឹក ការផ្តល់ប្រឹក្សាគរុកោសល្យ ជាដើម
- រៀបចំការបង្រៀន និងការសង្កេតមើលគ្នាជាដៃគូ ឬជាក្រុម
- រៀបចំកិច្ចប្រជុំបច្ចេកទេស
- រៀបចំសិក្ខាសាលាតាមសាលារៀន ក្រោមការសម្របសម្រួលរបស់គណៈកម្មការ ឬអ្នកផ្តល់សេវា អវប ដូចជាគ្រឹះស្ថានអប់រំគ្រូបង្រៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ អង្គការក្រៅរដ្ឋាភិបាល
- រក្សាកំណត់ត្រាអំពីសកម្មភាព អវប ដែលបានធ្វើ និងចំនួនក្រេឌីតដែលបានទទួល
- រក្សាកំណត់ត្រាដែលបង្ហាញពីលទ្ធផលនៃការវាយតម្លៃ
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃក្រេឌីត អវប ដែលទទួលបានជូនការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS (ក្នុងករណីសាលារៀនធំៗដែលមានបរិក្ខារចាំបាច់ និងអាចភ្ជាប់អ៊ីនធឺណេតបាន អាចបញ្ចូលព័ត៌មាននេះទៅក្នុងប្រព័ន្ធ HRMIS ដោយផ្ទាល់ក្នុងសាលារៀន)
- ពិនិត្យតាមដាន និងវាយតម្លៃ អវប ដែលអនុវត្តនៅកម្រិតសាលារៀនជារៀងរាល់ឆ្នាំ។

គួរមានការបញ្ចូលផែនការសិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀនទៅក្នុងផែនការកែលម្អ ឬអភិវឌ្ឍសាលារៀនប្រចាំឆ្នាំ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គណៈកម្មការ អវប នៅតាមសាលារៀនគួរចងក្រងបណ្ដាញជាមួយនឹងកម្រងសាលាបឋមសិក្សា ឬបណ្ដាញវិទ្យាល័យធនធាន ដើម្បីចែករំលែកគំនិត សហការអនុវត្តសកម្មភាព និងបង្កើនប្រសិទ្ធភាពចំណាយ។

សកម្មភាព អវប មួយចំនួនត្រូវអនុវត្តនៅក្នុងកម្រងសាលារៀនដែលផ្តល់លទ្ធភាពឱ្យគ្រូបង្រៀន និងនាយកសាលា មកពីសាលារៀនជាច្រើន អាចចូលរួមនៅក្នុងសកម្មភាព អវប ដែលផ្តល់ដោយអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាព និងមានការសន្សំសំចៃថវិកា។ សកម្មភាព អវប ដែលអាចធ្វើឡើងនៅកម្រិតកម្រងសាលារៀន៖

- នាយកសាលាសហការគ្នាវាយតម្លៃពីតម្រូវការ និងការរៀបចំកម្មវិធី អវប
- ការរៀបចំផែនការ ការគ្រប់គ្រង និងការសម្របសម្រួលសកម្មភាព អវប នៅកម្រិតកម្រងសាលារៀន
- សិក្ខាសាលានៅតាមកម្រងសាលារៀនដោយមានការសម្របសម្រួលពីកម្រងសាលារៀន ឬអ្នកផ្តល់សេវា អវប ដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាល ការិយាល័យគ្រប់គ្រង អវប
- ការបង្វឹក និងការផ្តល់ប្រឹក្សាគរុកោសល្យ
- ការធ្វើទស្សនកិច្ចនៅតាមសាលារៀន រយៈពេលខ្លី ដើម្បីរៀនពីបទពិសោធន៍ និងឧត្តមានុវត្តន៍

សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀនឬកម្រងសាលារៀនបង្កើតឡើងដើម្បីផ្តល់លទ្ធភាពឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមកក្នុងគោលបំណងកែលម្អការបង្រៀន ការដឹកនាំ និងការអនុវត្តការងារអប់រំ។ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អាចបញ្ចូលសកម្មភាពបង្វឹក និងផ្តល់ប្រឹក្សាគរុកោសល្យដែលកំពុងអនុវត្តនៅតាមសាលារៀននាពេលបច្ចុប្បន្ន ឬគ្រោងអនុវត្តនាពេលអនាគត ដោយគ្រូផ្តល់ប្រឹក្សាគរុកោសល្យនៅតាមសាលារៀនផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនដែលទើបចេញថ្មី និងផ្តល់ការបង្វឹកដល់សហការីរបស់ខ្លួន។ សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតកម្រងសាលារៀនដែលផ្តោតលើនាយកសាលា ផ្តល់លទ្ធភាពឱ្យនាយកសាលាមកពីតាមសាលារៀនជាច្រើននៅក្នុងកម្រងសាលារៀន អាចចែករំលែកបទពិសោធន៍ និងធនធានជាមួយគ្នា ក៏ដូចជា ជួយគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្នាទៅវិញទៅមក។ សហគមន៍សិក្សាវិជ្ជាជីវៈគួរទទួលបានការគាំទ្រពីអ្នកផ្តល់ប្រឹក្សា ឬគ្រូបង្វឹកនៅថ្នាក់ភូមិភាគឬថ្នាក់ខេត្តមានបទពិសោធន៍ ដែលគេហៅថាអ្នកផ្តល់ប្រឹក្សាដែលមានបទពិសោធន៍ ឬបង្គោល។

### ៣.១.២ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលរវាងសាលារៀន ថ្នាក់រាជធានី ខេត្ត និងជាតិ។ មន្ត្រីបង្គោលទទួលបន្ទុក អវប នៅកម្រិតការិយាល័យ អយក ក្រុង ស្រុកខណ្ឌ ជាអ្នកសម្របសម្រួល និងបញ្ជូនព័ត៌មានពីសាលារៀន ឬកម្រងទៅកាន់មន្ទីរ អយក រាជធានី ខេត្ត។

ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវបំពេញតួនាទីដូចខាងក្រោម៖

- ប្រមូលទិន្នន័យ អវប និងទិន្នន័យវាយតម្លៃទៀងទាត់ពីសាលារៀន និងបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS ឬផ្ញើទៅកាន់មន្ទីរ អយក រាជធានី ខេត្ត ប្រសិនបើពុំមានសម្ភារបរិក្ខារ ដើម្បីបញ្ចូលទិន្នន័យ
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដល់នាយកសាលា និងគណៈកម្មការ អវប ក្នុងការវាយតម្លៃគ្រូបង្រៀន ការវាយតម្លៃលើតម្រូវការ អវប ជួយគ្រូបង្រៀនក្នុងការគ្រប់គ្រងកម្រងស្នាដៃវិជ្ជាជីវៈ ការរក្សាកំណត់ត្រាអាជីព និងសកម្មភាពដទៃទៀត

- ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធ អវប ទៅកាន់សាលារៀន កម្រងសាលារៀន និងរំឭកសាលារៀន កម្រងសាលារៀនអំពីនីតិវិធី និងកាលបរិច្ឆេទកំណត់ដើម្បីចុះឈ្មោះគ្រូបង្រៀនឱ្យចូលរួមនៅក្នុងសកម្មភាព អវប
- សម្របសម្រួលសកម្មភាព អវប ដែលមានការទទួលស្គាល់គុណភាព
- ចូលរួមធានាគុណភាព សកម្មភាព អវប
- វាយតម្លៃនាយកសាលានៅកម្រិតគ្រឹះស្ថានសិក្សា ដោយសម្របសម្រួលជាមួយនឹងគ្រឹះស្ថានអប់រំគ្រូបង្រៀនទៅតាមការចាំបាច់
- ពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីដែលអនុវត្តនៅតាមសាលារៀន និងតាមកម្រងសាលារៀន។

### ៣.១.៣ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ធ្វើការសម្របសម្រួលរវាងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងថ្នាក់ជាតិ។ មន្ត្រីបង្គោលទទួលបន្ទុក អវប របស់មន្ទីរ អយក រាជធានី ខេត្ត ជាអ្នកសម្របសម្រួល និងបញ្ជូនព័ត៌មានរវាងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងការិយាល័យគ្រប់គ្រង អវប និងទទួលខុសត្រូវបំពេញមុខងារដូចខាងក្រោម៖

- ប្រមូលទិន្នន័យ អវប និងទិន្នន័យវាយតម្លៃតាមវដ្តទៀងទាត់ពីការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងបញ្ចូលក្នុងប្រព័ន្ធ HRMIS
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដល់មន្ត្រីបង្គោលទទួលបន្ទុក អវប របស់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ផ្តោតលើបញ្ហាបច្ចេកទេសនៅក្នុងប្រព័ន្ធ អវប
- ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធ អវប ដល់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងរំឭកការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ អំពីនីតិវិធី និងកាលបរិច្ឆេទកំណត់សម្រាប់ចុះឈ្មោះគ្រូបង្រៀនឱ្យចូលរួមនៅក្នុងសកម្មភាព អវប
- គាំទ្រ និងពិនិត្យតាមដានសកម្មភាព អវប ដែលត្រូវបានទទួលស្គាល់គុណភាព
- ចូលរួមធានាគុណភាពដល់សកម្មភាព អវប
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី អវប នៅតាមសាលារៀន និងកម្រងសាលារៀន នៅថ្នាក់រាជធានី ខេត្ត។

### ៣.១.៤ ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធ HRMIS

ការិយាល័យគ្រប់គ្រង អវប គឺជាការិយាល័យមួយស្ថិតក្រោមនាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលខុសត្រូវលើការគ្រប់គ្រង ចាត់ចែង និងធ្វើលិខិតបទដ្ឋានគតិយុត្តគ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធ អវប។ ការិយាល័យគ្រប់គ្រង អវប បែងចែកជា ៣ផ្នែក៖ (១) ផ្នែកគ្រប់គ្រងទិន្នន័យ និងក្រេឌីត អវប (២)ផ្នែកកំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលមានគុណភាព រួមមានស្តង់ដាអប្បរមា ការទទួលស្គាល់ និងការធានាគុណភាពនិងរៀបចំថវិកា អវប និង (៣) ផ្នែកគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ។ ផ្នែកទាំង៣នេះ ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងផ្នែកដែលពាក់ព័ន្ធនៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ផ្នែកគ្រប់គ្រងទិន្នន័យ និងក្រេឌីត អវប ទទួលខុសត្រូវលើការរក្សាទិន្នន័យក្រេឌីត អវប ដែលគ្រូបង្រៀន បានទទួល និងរក្សាទិន្នន័យសេវា អវប (សូមមើលឧបសម្ព័ន្ធទី១១ ស្តីពីតួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រង អវប ដែលកំណត់លម្អិតពីតួនាទីរបស់ផ្នែកទាំង៣) ដោយប្រើប្រាស់ម៉ូឌុល អវប នៅក្នុងប្រព័ន្ធ HRMIS របស់ក្រសួងអប់រំ យុវជន និងកីឡា។ ផ្នែកនេះទទួលខុសត្រូវលើការចេញវិញ្ញាបនបត្រ អវប រៀងរាល់ ៥ឆ្នាំម្តង ឬទៅតាមការស្នើសុំ ដោយបង្ហាញពី អវប ដែលគ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំម្នាក់ៗបានបញ្ចប់ដោយជោគជ័យ។

ផ្នែកកំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានស្តង់ដាអប្បរមាការទទួលស្គាល់ និងការធានាគុណភាពនិងរៀបចំថវិកា អវប មានតួនាទីគ្រប់គ្រង និងធ្វើបញ្ញត្តិកម្មសកម្មភាព អវប ដូចជា កំណត់លក្ខណៈវិនិច្ឆ័យនៃសេវា អវប ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវាសកម្មភាព អវប និងផ្តល់ការធានាគុណភាពនៅគ្រប់កម្រិតទាំងអស់។

ផ្នែកគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំមានតួនាទី គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មានដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដូចជាការផ្សព្វផ្សាយបញ្ជីសេវា អវប ប្រចាំឆ្នាំដែលមានសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ។ ការទទួលខុសត្រូវរបស់ការិយាល័យគ្រប់គ្រង អវប៖

- រៀបចំ អនុវត្ត និងត្រួតពិនិត្យគោលនយោបាយនិងផែនការសកម្មភាព អវប
- សម្របសម្រួល និងធ្វើការវាយតម្លៃលើតម្រូវការ អវប
- សម្របសម្រួលការទទួលស្គាល់គុណភាពសកម្មភាព និងអ្នកផ្តល់សេវា អវប (ស្ថាប័ន និងគ្រូឧទ្ទេស)
- ផលិត និងផ្សព្វផ្សាយប្រតិទិនសេវា អវប ប្រចាំឆ្នាំ
- ផ្តល់ការធានាគុណភាព អវប
- គ្រប់គ្រងចាត់ចែងការផ្តល់ថវិកា អវប នៅកម្រិតសាលារៀន
- ផ្សព្វផ្សាយ និងត្រួតពិនិត្យការចុះឈ្មោះចូលរួមនៅក្នុងសមាគមន៍សិក្សាវិជ្ជាជីវៈ
- ផ្សព្វផ្សាយ និងត្រួតពិនិត្យការចុះបញ្ជីព្រឹត្តិបត្រឈ្មោះចូលរួម នៅក្នុងព្រឹត្តិបត្រព័ត៌មាន និងព្រឹត្តិបត្រវិជ្ជាជីវៈ
- រៀបចំសកម្មភាព អវប សម្រាប់បុគ្គលិកអប់រំ
- ពិនិត្យតាមដាន និងផ្តល់ការធានាគុណភាពដល់ការវាយតម្លៃគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំប្រចាំឆ្នាំ
- ពិនិត្យតាមដាន និងផ្តល់ការធានាគុណភាពដល់ការវាយតម្លៃសកម្មភាព អវប ដែលផ្តល់ដោយអ្នកផ្តល់សេវា អវប និងផ្តល់ក្រេឌីត។

### ៣.១.៥ អ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ស្ថាប័ន ឬបុគ្គលមានសិទ្ធិស្នើសុំការទទួលស្គាល់គុណភាពតាមកម្រិតជំនាញផ្សេងៗគ្នា ឬអាចបំពេញតួនាទីជាដៃគូសហការក្នុងការផ្តល់សេវា អវប ក្នុងករណីស្ថាប័នឬបុគ្គលនោះបំពេញបានតាមលក្ខខណ្ឌដូចបាន

កំណត់នៅក្នុងដំណើរការផ្តល់ការទទួលស្គាល់គុណភាព (សូមមើលឧបសម្ព័ន្ធទី៨) ។ ស្ថាប័ន ឬបុគ្គលទាំងនោះរួមមាន៖

- គ្រឹះស្ថានអប់រំគ្រូបង្រៀន
- គ្រឹះស្ថានឧត្តមសិក្សា
- នាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ដៃគូអភិវឌ្ឍន៍
- អង្គការក្រៅរដ្ឋាភិបាលជាតិ
- អ្នកផ្តល់សេវា អវប ដើម្បីប្រាក់ចំណេញ
- អ្នកឯកទេសអប់រំ
- គ្រូបង្រៀន និងគ្រូឧទ្ទេសដែលមានបទពិសោធន៍
- បុគ្គលិកអប់រំមានឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីព

តាមរយៈការប្រើប្រាស់អភិក្រមជាជំហានៗនេះ អ្នកផ្តល់សេវា អវប ដើម្បីប្រាក់ចំណេញ គ្រូបង្រៀន និងគ្រូឧទ្ទេសដែលមានបទពិសោធន៍ និងអ្នកឯកទេសអប់រំ មានសិទ្ធិទទួលបានការទទួលស្គាល់គុណភាពផ្តល់សេវា អវប ក្នុងដំណាក់កាលទី២ ដែលអនុវត្តចាប់ឆ្នាំ២០២៥ តទៅ។

គ្រូឧទ្ទេសដែលកំពុងបម្រើការនៅក្នុងស្ថាប័នផ្តល់សេវា អវប ត្រូវតែមានបញ្ជីឈ្មោះ និងបញ្ជាក់ពីកម្រិតគុណវុឌ្ឍិ ឱ្យបានច្បាស់លាស់ ដែលជាផ្នែកមួយនៃការផ្តល់ការទទួលស្គាល់គុណភាពដល់ស្ថាប័ន។

## ៣.២ លំហូរព័ត៌មានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គន្លងអាជីពគ្រូបង្រៀន និង HRMIS

ប្រព័ន្ធ អវប ពាក់ព័ន្ធនឹងតួអង្គ និងស្ថាប័នជាច្រើន ដែលព័ត៌មានត្រូវឆ្លងកាត់ដើម្បីឱ្យប្រព័ន្ធនេះអាចដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ រូបទី៣ ខាងក្រោមបង្ហាញពីដំណើរការនៃលំហូរព័ត៌មាន ដោយគ្រូបង្រៀនជាអ្នកចូលរួមធ្វើសកម្មភាព អវប ហើយក្រេឌីតបានមកពី អវប នេះត្រូវបានកត់ត្រាក្នុងប្រព័ន្ធ HRMIS និងបង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀន ក្នុងការសន្សំក្រេឌីតទទួលបានពីការចូលរួមសកម្មភាព អវប ដោយជោគជ័យ ហើយវាជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់ដំឡើងឋានៈវិជ្ជាជីវៈនៅក្នុងគន្លងអាជីពគ្រូបង្រៀន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*រូបភាពទី៣៖ ប្រព័ន្ធលំហូរក្រេឌីត អវប និងទំនាក់ទំនងជាមួយ TCP (ប្រភព៖ **B. Khan** និង **S. Doctors** ចម្លងចេញពីឯកសារពិពណ៌នាអំពីម៉ូឌុល អវប)*



**ប្រព័ន្ធលំហូរក្រេឌីត អវប និងទំនាក់ទំនងជាមួយគន្លងអាជីពគ្រូបង្រៀន**

**១. គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ** គឺជាក្រុមគោលដៅនៃប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀន មានសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមសកម្មភាព អវប ដែលរៀបចំដោយមានគោលបំណងច្បាស់លាស់ និងទៀងទាត់ ព្រមទាំងមានឱកាសដាក់ពាក្យសុំឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន និងតាមលក្ខណៈវិនិច្ឆ័យចាំបាច់។

**២. គណៈកម្មការ អវប** នៅតាមសាលារៀនត្រូវសម្របសម្រួលផ្ដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន និងនាយកសាលា រៀបចំវាយតម្លៃលើតម្រូវការ អវប របស់គ្រូបង្រៀនម្នាក់ៗ តម្រូវការនៅក្នុងសាលារៀន និងត្រូវផ្សព្វផ្សាយព័ត៌មានអំពីឱកាស អវប ដោយសហការជាមួយអ្នកផ្ដល់សេវា អវប។

**៣. អវប មានរចនាសម្ព័ន្ធច្បាស់លាស់ អវប រៀនដោយខ្លួនឯង កម្មវិធីវិក្រឹតការ និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន៖** អវប អាចរៀបចំឡើងដោយអ្នកផ្ដល់សេវា មានរចនាសម្ព័ន្ធច្បាស់លាស់ និង ឬ ដែលសាមីខ្លួនជ្រើសរើសដោយខ្លួនឯង។ ឧទាហរណ៍៖ សកម្មភាព អវប ដែលរៀបចំដោយអ្នកផ្ដល់សេវា ឬកម្មវិធីវិក្រឹតការ រួមមានវគ្គបណ្ដុះបណ្ដាល ឬសិក្ខាសាលាដែលផ្ដល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ដូចជាវគ្គបណ្ដុះបណ្ដាលនៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនជាដើម។ ឧទាហរណ៍៖ សកម្មភាព អវប រៀនខ្លួនឯង រួមមានការបញ្ចប់វគ្គសិក្សាអនឡាញបើកទូលាយ ការអានអត្ថបទស្រាវជ្រាវ និងការសរសេររបាយការណ៍សង្ខេបស្ដីពីការយកចំណេះដឹងដែលទទួលបានទៅអនុវត្តនៅក្នុងសាលារៀន ការស្រាវជ្រាវប្រតិបត្តិ ឬការដឹកនាំកិច្ចប្រជុំចែករំលែកបទពិសោធន៍នៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។

**៤. ការទទួលក្រេឌីត អវប ៖** បន្ទាប់ពីបានបញ្ចប់សកម្មភាព អវប ដោយជោគជ័យ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ នឹងទទួលបានក្រេឌីត អវប។ អ្នកផ្ដល់សេវាដែលមានការទទួលស្គាល់គុណភាព ត្រូវផ្ទៀងផ្ទាត់ និងបញ្ជាក់ឱ្យបានត្រឹមត្រូវចំពោះ អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយគណៈកម្មការ អវប នៅតាមសាលារៀន ជាអ្នកផ្ទៀងផ្ទាត់លើក្រេឌីតដែលបានពីសកម្មភាព អវប រៀនដោយខ្លួនឯង។ ក្រេឌីតទាំងនេះត្រូវបានបញ្ចូលទៅក្នុងកំណត់ត្រាអាជីព និងកត់ត្រាក្នុងប្រព័ន្ធ HRMIS។

**៥. ការវាយតម្លៃតាមវដ្តទៀងទាត់ និងលទ្ធផល៖** គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំទាំងអស់ត្រូវរៀបចំការវាយតម្លៃតាមវដ្តទៀងទាត់ជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់ដើម្បីវាស់វែងការបំពេញការងារធៀបនឹងចំណុចដៅដែលបានដាក់ចេញកាលពីឆ្នាំមុន ទទួលស្គាល់ពីលទ្ធផលដែលសម្រេចបាន កំណត់ពីបញ្ហាដែលត្រូវធ្វើការកែលម្អបន្ថែម និងដើម្បីកំណត់គោលដៅ អវប សម្រាប់ឆ្នាំបន្ទាប់។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ តាមដានការវាយតម្លៃតាមវដ្តទៀងទាត់នេះ។ មន្ទីរ អយក រាជធានី ខេត្ត ពិនិត្យតាមដានការសម្របសម្រួល និងការគាំទ្ររបស់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌដែលផ្ដល់ដល់សាលារៀនក្នុងការវាយតម្លៃតាមវដ្តទៀងទាត់ និងបញ្ចូលលទ្ធផលវាយតម្លៃទៅក្នុងប្រព័ន្ធ HRMIS។

**៦. ការត្រៀមឡើងឋានៈវិជ្ជាជីវៈតាមគន្លងអាជីពគ្រូបង្រៀន៖** អ្នកសន្សំបានក្រេឌីតពី អវប ហើយមានទំនុកចិត្តថាពិតជាបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឋានៈវិជ្ជាជីវៈនីមួយៗស្របតាមគន្លងអាជីពគ្រូបង្រៀន អាចទទួលការវាយតម្លៃដំឡើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន។ អ្នកអនុវត្ត អវប អាចបើកមើលព័ត៌មាន ឬពិន្ទុបច្ចុប្បន្នភាពផ្ទាល់ខ្លួនតាមកម្មវិធីទូរស័ព្ទចល័ត ហើយព័ត៌មានទាំងនោះនឹងបញ្ជាក់ពីលទ្ធភាពដែលអាចទទួលបានជោគជ័យក្នុងការវាយតម្លៃដំឡើងឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន។

**៧. ការវាយតម្លៃក្នុងគន្លងអាជីពគ្រូបង្រៀន និងការសម្រេចចិត្ត៖** អ្នកត្រៀមឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន ត្រូវឆ្លងកាត់ការវាយតម្លៃ "កម្រិតខ្ពស់"។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ទទួលពាក្យសុំវាយតម្លៃ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

រួចបញ្ជូនទៅមន្ទីរ អយក រាជធានី ខេត្តដើម្បីស្នើសុំការឯកភាព និងដំឡើងឋានៈវិជ្ជាជីវៈ ជូនទៅគណៈកម្មការ អវប។ ក្នុងអំឡុងពេលនៃការវាយតម្លៃនេះ បេក្ខជនបង្ហាញភស្តុតាងបញ្ជាក់ថាពួកគេពិតជាបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដើម្បីឡើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន។ គណៈកម្មការធ្វើការវាយតម្លៃ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងបញ្ចូលលទ្ធផលវាយតម្លៃក្នុងប្រព័ន្ធ HRMIS។ ប្រសិនបើការវាយតម្លៃនេះជោគជ័យ បេក្ខជនទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកម្រិតបន្ទាប់ទៀត។

**៨. ការមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យ គន្លងអាជីពគ្រូបង្រៀន ៖** បេក្ខជនមិនទទួលបានជោគជ័យអាចដាក់ពាក្យសារជាថ្មីនៅឆ្នាំបន្ទាប់ ដោយបេក្ខជនត្រូវខិតខំកែលម្អ ផ្នែកដែលទទួលពិន្ទុក្រោមស្តង់ដា។

**៩. សាលារៀន៖** អវប ក៏អាចរៀបចំនៅកម្រិតសាលារៀនផងដែរ មានន័យថាសកម្មភាព អវប ជាច្រើនអាចធ្វើឡើងនៅក្នុងសាលារៀន ដូច្នេះ អវប ទាំងនេះគឺពាក់ព័ន្ធផ្ទាល់ជាមួយនឹងសកម្មភាព និងលទ្ធផលនៃការបំពេញការងារនៅក្នុងថ្នាក់រៀន។ ការវាយតម្លៃគ្រូបង្រៀនតាមវដ្តទៀងទាត់ត្រូវធ្វើឡើងនៅកម្រិតសាលារៀន។

**១០. កម្រងសាលារៀន៖** កម្រងសាលារៀន គាំទ្រកម្មវិធីប្រឹក្សាគរុកោសល្យ និងសកម្មភាព អវប ដែលផ្តល់ដោយអ្នកផ្តល់សេវាដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលមានការទទួលស្គាល់គុណភាព ព្រមទាំងសម្របសម្រួលទំនាក់ទំនងរវាងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងសាលារៀនដូចជា ការផ្សព្វផ្សាយព័ត៌មានជូនដល់សាលារៀន និងការបញ្ជូនទិន្នន័យស្តីពី អវប របស់គ្រូបង្រៀនម្នាក់ៗទៅកាន់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ដែលបន្ទាប់មកត្រូវបញ្ជូនព័ត៌មាននេះបន្តទៀតទៅកាន់មន្ទីរ អយក រាជធានី ខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។

**១១. ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ៖** មានតួនាទីសំខាន់សម្រាប់ផ្តល់ព័ត៌មានពីឱកាស និងក្រេឌីត អវប ទៅសាលារៀន ក៏ដូចជាផ្តល់ព័ត៌មានពី អវប ដែលគ្រូបង្រៀនម្នាក់ៗបានចូលរួម និងក្រេឌីតដែលទទួលបាន ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS តាមរយៈមន្ទីរ អយក រាជធានី ខេត្ត។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ អាចតែងតាំងមន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើ អវប និងគន្លងអាជីពគ្រូបង្រៀន។

**១២. មន្ទីរ អយក រាជធានី ខេត្ត៖** គ្រប់គ្រងប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀននៅថ្នាក់ក្រោមជាតិ និងផ្តល់ការទំនាក់ទំនងរវាងក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ។ មន្ទីរ អយក រាជធានី ខេត្តត្រូវសម្របសម្រួលគ្រប់សកម្មភាព អវប ជាផ្លូវការ។ មន្ត្រីបង្គោលរបស់មន្ទីរ អយក រាជធានី ខេត្ត ត្រូវរៀបចំ និងផ្សព្វផ្សាយប្រតិទិនពីឱកាស អវប នៅកម្រិតរាជធានី ខេត្ត។ មន្ទីរ អយក រាជធានី ខេត្តអាចចាត់តាំងមន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើការងារ អវប និងគន្លងអាជីពគ្រូបង្រៀន។

**១៣. ការិយាល័យគ្រប់គ្រង អវប៖** គ្រប់គ្រងទិន្នន័យ អវប និង TCP ទាំងអស់នៅថ្នាក់ជាតិ រៀបចំគោលនយោបាយ កំណត់ថវិកាគាំទ្រដល់សកម្មភាព អវប រាប់បញ្ចូលទាំងសកម្មភាព អវប នៅតាមសាលារៀន ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវានិងកម្មវិធី អវប ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីឱកាស អវប។ ការិយាល័យគ្រប់គ្រង អវប ផ្តល់ការគាំទ្រ និងសម្របសម្រួលសកម្មភាពនៅថ្នាក់ក្រោមជាតិតាមរយៈបណ្តាញរបស់ក្រសួងអប់រំ យុវជន និងកីឡារួមមាន នាយកដ្ឋានជំនាញ មន្ទីរ អយក រាជធានី ខេត្ត ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន និងសាលារៀន។

**១៤. HRMIS (ម៉ូឌុល អវប និងគន្លងអាជីពគ្រូបង្រៀន) ៖** គ្រប់គ្រងរាល់ទិន្នន័យទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិជ្ជាជីវៈ និងវឌ្ឍនភាពអាជីពរបស់បុគ្គលិកអប់រំ។

**១៥. ការកត់ត្រាក្រេឌីត អវប និងកំណត់ត្រាអាជីព៖** រាល់សកម្មភាព អវប ទាំងអស់ត្រូវមានការកត់ត្រាចំនួនក្រេឌីត ប្រធានបទ ខ្លឹមសារសំខាន់ៗ និងមានការចេញផ្សាយកំណត់ត្រាអាជីពដែលបង្ហាញពីព័ត៌មាននៃការអនុវត្ត អវប រយៈពេល ៥ឆ្នាំម្តង ឬទៅតាមភាពចាំបាច់។

**១៦. ការឡើងឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន៖** មានការកត់ត្រាទិន្នន័យអំពីគុណវុឌ្ឍិ បទពិសោធន៍ លទ្ធផលនៃការវាយតម្លៃ និង អវប របស់បុគ្គលិកអប់រំ ដើម្បីចេញជារបាយការណ៍ដែលបង្ហាញព័ត៌មានលម្អិតស្តីពីពិន្ទុសម្រាប់ទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកាន់កម្រិតបន្ទាប់ក្នុងគន្លងអាជីពគ្រូបង្រៀន។

**១៧. នាយកដ្ឋានជំនាញ គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា និងអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់សេវា អវប កម្មវិធីដំឡើងគុណវុឌ្ឍិ កម្មវិធីវិក្រឹតការឯកជន ៖** អ្នកផ្តល់សេវា អវប មានការទទួលស្គាល់គុណភាពពីការិយាល័យគ្រប់គ្រង អវប មានដូចជា នាយកដ្ឋានក្រោមឱវាទក្រសួង អយក គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់សេវា អវប កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន និងកម្មវិធីវិក្រឹតការឯកជនផ្សេងទៀតជាអ្នកផ្តល់សេវា អវប ផ្លូវការអាចធ្វើបាននៅតាមកម្រិតសាលារៀន។

**១៨. គ្រូបង្វឹក គ្រូប្រឹក្សា និងគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិ៖** ជាបុគ្គលដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យជាអ្នកផ្តល់សេវាអប់រំ និងបានការទទួលស្គាល់គុណភាពពី ការិយាល័យគ្រប់គ្រង អវប អាចផ្តល់សេវា អវប នៅសាលារៀនដោយផ្ទាល់ ឬតាមរយៈគ្រឹះស្ថានដែលជាអ្នកផ្តល់សេវា អវប ផងដែរ។

**១៩. ការទទួលស្គាល់គុណភាព ការធានាគុណភាព និងការពិនិត្យតាមដានវាយតម្លៃ៖** ការិយាល័យគ្រប់គ្រង អវប សហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធពិសេសនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងគណៈកម្មការទទួលស្គាល់គុណភាពអប់រំ ត្រូវធានាខុសត្រូវលើការទទួលស្គាល់គុណភាព ការធានាគុណភាព និងការតាមដានវាយតម្លៃប្រព័ន្ធ អវប ជាពិសេស លើការផ្តល់សេវា អវប ដែលផ្តល់ដោយបុគ្គល និងជាស្ថាប័នផ្តល់សេវា អវប។

**២០. ការកំណត់លក្ខណៈវិនិច្ឆ័យ ការទទួលស្គាល់គុណភាព និងក្រុមធានាគុណភាព៖** ការិយាល័យគ្រប់គ្រង អវប ធ្វើការសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធដើម្បីកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់សេវា អវប ប្រកបដោយគុណភាព ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៤. បែបបទ និងយន្តការទទួលស្គាល់គុណភាពអ្នកផ្តល់សេវា និងសកម្មភាព អវប

អ្នកផ្តល់សេវា អវប ត្រូវតែមានការទទួលស្គាល់ពី ការិយាល័យគ្រប់គ្រង អវប ដើម្បីជានាឱ្យបានទៅតាមលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់អ្នកផ្តល់សេវា អវប។ គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា នាយកដ្ឋានជំនាញ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់សេវា អវប ដើម្បីប្រាក់ចំណេញ គ្រូបង្រៀន គ្រូឧទ្ទេសដែលមានបទពិសោធន៍ ឬអ្នកឯកទេសអប់រំ អាចទទួលបានការទទួលស្គាល់ជាអ្នកផ្តល់សេវា អវប ក្នុងករណីបំពេញបានតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់សម្រាប់ដំណើរការផ្តល់ការទទួលស្គាល់គុណភាព។

### ៤.១ គ្រឹះស្ថាន និងដំណើរការ

#### ៤.១.១ អង្គភាពដែលផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងសកម្មភាពអវប

*គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវា អវប* មានសមាសភាពមកពីថ្នាក់ដឹកនាំក្រសួង អយក តំណាងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) និងតំណាងមកពីនាយកដ្ឋានពាក់ព័ន្ធ ជាអ្នកផ្តល់សិទ្ធិអនុញ្ញាតឱ្យស្ថាប័នផ្តល់សេវា និងបុគ្គលផ្តល់សេវា អវប សិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗ។ ការិយាល័យគ្រប់គ្រង អវប ជាអ្នកដើរតួដ៏សំខាន់ក្នុងការបំពេញមុខងារគ្រប់គ្រង ចាត់ចែងផ្តល់ការទទួលស្គាល់គុណភាពជាប្រចាំ។ នាយកដ្ឋានជំនាញពាក់ព័ន្ធ ការិយាល័យគ្រប់គ្រង អវប និង ACC សហការរៀបចំ និងប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ឧបករណ៍ និងនីតិវិធី សម្រាប់ផ្តល់ការទទួលស្គាល់គុណភាព។ *គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវា អវប* ពិសេស ការិយាល័យគ្រប់គ្រង អវប មានសិទ្ធិអញ្ជើញតំណាងស្ថាប័នផ្តល់សេវា និងបុគ្គលផ្តល់សេវា អវប មកបំភ្លឺពីការដាក់ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់គុណភាព ឬបើកវគ្គ អវប ក្នុងករណីចាំបាច់។

#### ៤.១.២ នីតិវិធីទទួលស្គាល់គុណភាព

ការដាក់ពាក្យសុំការទទួលស្គាល់គុណភាពជាអ្នកផ្តល់សេវា ឬបើកវគ្គ អវប អាចទាញយកទម្រង់ពាក្យស្នើសុំពីគេហទំព័ររបស់ការិយាល័យគ្រប់គ្រង អវប (ឧបសម្ព័ន្ធទី៨) រួចបំពេញព័ត៌មាន និងបញ្ជូនទៅការិយាល័យគ្រប់គ្រង អវប ដោយមានភស្តុតាងគាំទ្រគ្រប់គ្រាន់។ អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញឱ្យបានតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់គុណភាព និងមានភស្តុតាងជាក់លាក់។ ក្នុងករណីមានភ័ស្តុតាងជាទម្រង់ឯកសារច្រើនទំព័រ គួរតែបញ្ជាក់ពីផ្នែកដែលពាក់ព័ន្ធ និងលេខរៀងទំព័រ។ បន្ទាប់ពីការពិនិត្យពាក្យស្នើសុំ និងភ័ស្តុតាងដោយប្រើឧបករណ៍ពាក់ព័ន្ធ (ឧបសម្ព័ន្ធទី៨) បុគ្គលិកការិយាល័យគ្រប់គ្រង អវប នឹងអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬក៏សុំផ្តល់ភ័ស្តុតាងបន្ថែមក្នុងករណីចាំបាច់ តែបើពិនិត្យឃើញថាបានបំពេញតាមលក្ខខណ្ឌ ការិយាល័យគ្រប់គ្រង អវប នឹងបញ្ជូនទៅ *គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវា អវប* ដើម្បីសម្រេចចុងក្រោយ។ រយៈពេលនៃការផ្តល់លទ្ធផលស្នើសុំការទទួលស្គាល់គុណភាពយ៉ាងយូរ ២ខែគិតចាប់ពីពេលស្នើសុំដោយមានភ័ស្តុតាងគ្រប់គ្រាន់។ *រូបទី៤* ខាងក្រោមបង្ហាញពីដំណាក់នៅក្នុងនីតិវិធីទទួលស្គាល់គុណភាព។

## រូបទី៤: នីតិវិធីទទួលស្គាល់គុណភាព




## ៤.២ ការទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវា អវប

អ្នកផ្តល់សេវា អវប ត្រូវដាក់ពាក្យទៅកាន់ការិយាល័យគ្រប់គ្រង អវប ដើម្បីសុំការទទួលស្គាល់គុណភាព។ អ្នកផ្តល់សេវា អវប ដែលទទួលស្គាល់គុណភាពជាផ្លូវការ មានសិទ្ធិផ្តល់សកម្មភាព អវប។ អ្នកផ្តល់សេវាមានការទទួលស្គាល់ជាបណ្តោះអាសន្ន អាចផ្តល់សកម្មភាព អវប បានក្នុងអំឡុងពេលដែលអនុញ្ញាត ហើយត្រូវបំពេញនូវចំណុចខ្វះខាតមុនពេលដាក់ពាក្យស្នើសុំការទទួលស្គាល់ឡើងវិញ។ ប្រព័ន្ធ HRMIS និងគេហទំព័ររបស់ការិយាល័យគ្រប់គ្រង អវប ផ្តល់បញ្ជីអ្នកផ្តល់សេវា ដែលទទួលស្គាល់គុណភាព និងបញ្ជាក់ពីប្រភេទនៃការទទួលស្គាល់ (សូមមើលឧបករណ៍ផ្តល់ការទទួលស្គាល់គុណភាពនៅក្នុងឧបសម្ព័ន្ធទី៨)។ ការិយាល័យគ្រប់គ្រង អវប ត្រូវពិនិត្យលើពាក្យស្នើសុំ និងត្រូវធ្វើការងារជាមួយនឹងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យមើលពាក្យស្នើសុំទៅតាមការចាំបាច់ និងធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា។

ការវាយតម្លៃការទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវា អវប មានការសម្រេចចិត្តចំនួន ៣ប្រភេទ៖

- ការទទួលស្គាល់គុណភាពពេញសិទ្ធិ
- ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន ដោយរង់ចាំពិនិត្យមើលការកែលម្អចំណុចជាក់លាក់មួយចំនួន
- ការមិនទទួលស្គាល់គុណភាព

គណៈកម្មការនឹងជូនដំណឹងពីលទ្ធផលនៃការសម្រេចចិត្តដល់អ្នកស្នើសុំឱ្យទាន់ពេលវេលា ក្នុងរយៈពេលយ៉ាងយូរ ២ខែចាប់ពីថ្ងៃដាក់ពាក្យ។ នៅក្នុងករណីដែលមានការទទួលស្គាល់គុណភាពពេញសិទ្ធិ ឬការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន គ្រឹះស្ថាន ឬបេក្ខជនត្រូវផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈកម្មការវាយតម្លៃទទួលស្គាល់គុណភាពសេវា អវប ដល់អ្នកទទួលសេវា។ ក្នុងករណីដែលមានការផ្តល់ការទទួលស្គាល់គុណភាពជា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បណ្ដោះអាសន្ន គ្រឹះស្ថាន ឬបេក្ខជនអាចផ្ដល់សេវារយៈពេល ៣ឆ្នាំ គណៈកម្មការវាយតម្លៃតាមរយៈការិយាល័យគ្រប់គ្រង អវប បញ្ជូនព័ត៌មានត្រឡប់អំពីចំណុចកែលម្អចាំបាច់ និងក្របខណ្ឌពេលវេលាដែលត្រូវធ្វើការកែលម្អ ដើម្បីត្រៀមស្នើសុំការទទួលស្គាល់គុណភាពពេញសិទ្ធិនៅឆ្នាំបន្ទាប់ ដោយបង្ហាញភស្តុតាងបញ្ជាក់ពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលនៅមិនទាន់បានបំពេញកន្លងមក។ ពាក្យស្នើសុំថ្មីអាចនាំឱ្យមានការផ្ដល់ការទទួលស្គាល់គុណភាពប្រសិនបើមានការបំពេញទៅតាមគ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់ ឬការផ្ដល់ការទទួលស្គាល់គុណភាពអាចនៅជាបណ្ដោះអាសន្នម្ដងទៀតដោយរង់ចាំការកែលម្អបន្ថែម និងមានការប្រកាសពីក្របខណ្ឌពេលវេលាថ្មីដើម្បីបំពេញទៅតាមលក្ខខណ្ឌទាំងនេះ។ ស្ថាប័ន ឬបេក្ខជនអាចបន្តផ្ដល់សេវា អវប នៅក្នុងរយៈពេលនេះបាន ប៉ុន្តែក្រោយរយៈពេលនេះ ពួកគេត្រូវដាក់ពាក្យសុំថ្មី ដែលបង្ហាញភស្តុតាងពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលនៅមិនទាន់បានបំពេញ។ ស្ថាប័ន ឬបេក្ខជនដែលនៅមិនទាន់បានបំពេញតាមលក្ខណៈវិនិច្ឆ័យនៅពេលដាក់ពាក្យសុំជាលើកទី៣ នឹងពុំទទួលបានការទទួលស្គាល់គុណភាពឡើយ ហើយមិនអនុញ្ញាតឱ្យបន្តផ្ដល់សេវា អវប ។

ក្នុងករណីដែលមានការបដិសេធមិនផ្ដល់ការទទួលស្គាល់គុណភាព គណៈកម្មការវាយតម្លៃត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធដល់ស្ថាប័ន ឬបេក្ខជន។ ស្ថាប័ន ឬបេក្ខជនអាចដាក់ពាក្យស្នើសុំការទទួលស្គាល់គុណភាពជាថ្មីក្នុងរយៈពេលមួយឆ្នាំក្រោយ។ ពាក្យស្នើសុំថ្មីត្រូវបង្ហាញភស្តុតាងដែលឆ្លើយតបចំពោះបញ្ហាដែលនាំឱ្យមានការបដិសេធមិនផ្ដល់ការទទួលស្គាល់គុណភាព។

ឧបករណ៍ដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៨ អាចយកមកប្រើប្រាស់សម្រាប់ការទទួលស្គាល់គុណភាពស្ថាប័នផ្ដល់សេវា អវប ។ ឧបករណ៍ទាំងនេះត្រូវបានរៀបចំឡើងផ្អែកតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០ ស្តង់ដានាយកសាលារៀនឆ្នាំ២០១៧ ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀនឆ្នាំ២០១៦ ក្របខណ្ឌសមត្ថភាពគ្រូបង្រៀនអាស៊ីអាគ្នេយ៍ឆ្នាំ២០១៨ ក្របខណ្ឌសមត្ថភាពគ្រូបង្រៀនអាស៊ីអាគ្នេយ៍សម្រាប់សតវត្សរ៍ទី២១ និងស្តង់ដាសមត្ថភាពគ្រូបង្រៀនសម្រាប់ប្រទេសអាស៊ីអាគ្នេយ៍ឆ្នាំ២០១០។ ក្របខណ្ឌ និងផែនការសកម្មភាព អវប ទំព័រទី១៩ បញ្ជាក់យ៉ាងច្បាស់ថា ចាំបាច់ត្រូវកែសម្រួលស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន។

## ៤.៣ ការទទួលស្គាល់គុណភាពសកម្មភាព អវប

រាល់សកម្មភាព អវប ទាំងអស់ដែលផ្ដល់ដោយអ្នកផ្ដល់សេវា អវប ត្រូវតែឆ្លងកាត់ការទទួលស្គាល់គុណភាព។ សកម្មភាព អវប ដែលត្រូវបានទទួលស្គាល់គុណភាពជាបណ្ដោះអាសន្ន មានសុពលភាពតាមការកំណត់ដើម្បីរង់ចាំការបំពេញលក្ខខណ្ឌ។ ការិយាល័យគ្រប់គ្រង អវប ផ្សព្វផ្សាយបញ្ជីសេវាសកម្មភាព អវប ប្រចាំឆ្នាំដល់សាលារៀន និងគ្រូបង្រៀនតាមរយៈកម្មវិធីទូរស័ព្ទដៃ និងគេហទំព័ររបស់ការិយាល័យគ្រប់គ្រង អវប។

ពាក្យស្នើសុំ និងឧបករណ៍វាយតម្លៃសកម្មភាព អវប មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៨ ដែលប្រើប្រាស់សម្រាប់ផ្ដល់ការទទួលស្គាល់គុណភាពសកម្មភាព អវប។

អ្នកផ្ដល់សេវា អវប ត្រូវដាក់ពាក្យស្នើសុំទៅកាន់ការិយាល័យគ្រប់គ្រង អវប ដើម្បីស្នើសុំការទទួលស្គាល់គុណភាពដល់សកម្មភាព អវប នីមួយៗ ដោយភ្ជាប់មកនូវឯកសារគាំទ្រ។ ការិយាល័យគ្រប់គ្រង អវប ត្រូវពិនិត្យលើពាក្យសុំ និងត្រូវធ្វើការងារជាមួយនឹងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ នាយកដ្ឋានជំនាញពាក់ព័ន្ធដើម្បីពិនិត្យមើលផ្នែកដែលពាក់ព័ន្ធទៅតាមការចាំបាច់ និងធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា។ ស្ថាប័ន ឬបេក្ខជននឹងទទួលបានការជូនដំណឹងអំពីការសម្រេចចិត្តការទទួលស្គាល់គុណភាពពេញលេញ ឬជាបណ្ដោះអាសន្ន ហើយផ្សព្វផ្សាយសកម្មភាពរបស់ខ្លួនតាមរយៈខិត្តប័ណ្ណ គេហទំព័រ បញ្ជីសេវា អវប។

ការវាយតម្លៃការទទួលស្គាល់គុណភាពសកម្មភាព អវប មានការសម្រេចចិត្តចំនួន ៣ប្រភេទ៖

- ការទទួលស្គាល់គុណភាពពេញសិទ្ធិ
- ការទទួលស្គាល់គុណភាពជាបណ្ដោះអាសន្ន ដោយរង់ចាំពិនិត្យមើលការកែលម្អចំណុចជាក់លាក់មួយចំនួន
- ការមិនទទួលស្គាល់គុណភាព

បែបបទនៃការទទួលស្គាល់គុណភាពសកម្មភាព អវប ដូចគ្នានឹង ការទទួលស្គាល់គុណភាពគ្រឹះស្ថានផ្ដល់សេវា អវប ដែរ។

### ៤.៤ ការអនុវត្តលក្ខណៈវិនិច្ឆ័យកំណត់គុណភាពអប្បបរមា

ការរៀបចំសកម្មភាព អវប ត្រូវបំពេញទៅតាមតម្រូវការវិជ្ជាជីវៈរបស់គ្រូបង្រៀន និងនាយកសាលា ដែលជាក្រុមគោលដៅនៃសកម្មភាព អវប។ ប្រព័ន្ធក្រេឌីត អវប រៀបរាប់លម្អិតអំពីការកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ អវប ដែលរៀបចំសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅតាមកម្រិតនីមួយៗ ដែលមានបំណងដំឡើងគុណវុឌ្ឍិដល់កម្រិតបរិញ្ញាបត្រអប់រំ និងវឌ្ឍនភាពអាជីព។ លក្ខណៈវិនិច្ឆ័យចាំបាច់ត្រូវយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព និងងាយស្រួល ដើម្បីផ្ដល់ការទទួលស្គាល់គុណភាពដល់សកម្មភាព អវប និងការធានាគុណភាព។ ការអនុវត្តលក្ខណៈវិនិច្ឆ័យតម្រូវឱ្យប្រែក្លាយសេចក្ដីពិពណ៌នាដែលមានលក្ខណៈអរូបីដូចជា សេចក្ដីពិពណ៌នាអំពីចំណេះដឹង និងសមត្ថភាពឱ្យទៅជាសេចក្ដីពិពណ៌នាឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្ដែងដែលអាចយកទៅប្រើប្រាស់ ដើម្បីវាយតម្លៃអ្នកផ្ដល់សេវា អវប ឬសកម្មភាព អវប។

## ៥. ព័ត៌មាន និងការផ្សព្វផ្សាយដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ

ប្រព័ន្ធ អវប គឺជាវិធីថ្មីមួយ ដើម្បីបន្តផ្ដល់ការគាំទ្រដល់ការអប់រំគ្រូបង្រៀនដោយចាត់ទុកគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំជាស្នូលនៃដំណើរការប្រព័ន្ធ អវប។ ប្រព័ន្ធនេះតម្រូវឱ្យមានការផ្លាស់ប្ដូរវប្បធម៌ និងការផ្សព្វផ្សាយឱ្យបានច្បាស់លាស់ពីគោលបំណង គោលដៅ និងយន្តការ។ ការិយាល័យគ្រប់គ្រង អវប មានផ្នែកមួយដែលទទួលខុសត្រូវលើការផ្ដល់ព័ត៌មាន និងផ្សព្វផ្សាយ។

### ៥.១ ការផ្សព្វផ្សាយអំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ផ្នែកព័ត៌មាន និងផ្សព្វផ្សាយជាផ្នែកថែទាំគេហទំព័រ និងកម្មវិធីតាមទូរស័ព្ទដៃរបស់ការិយាល័យគ្រប់គ្រង អវប ដែលជាប្រភពផ្ដល់ព័ត៌មានបច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធ អវប ដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំតាមរយៈមន្ត្រីបង្គោលរបស់មន្ទីរ អយក រាជធានី ខេត្ត និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ។ ព័ត៌មានដែលផ្សព្វផ្សាយតាមមធ្យោបាយបែបនេះ រួមមាន៖

- សៀវភៅណែនាំ អវប ជាទម្រង់ជាឯកសារទន់ និងឯកសាររឹង
- ប្រតិទិនដែលបង្ហាញពីសកម្មភាព អវប ប្រចាំឆ្នាំ
- សហគមន៍សិក្សាវិជ្ជាជីវៈ និងព្រឹត្តិបត្រឬទិនានុប្បវត្តិ
- ប្រភពជាតុចូលសម្រាប់ អវប រៀនដោយខ្លួន និងមានការទទួលស្គាល់គុណភាពនាពេលអនាគត
- ឯកសារ និងសម្ភារៈបង្កើនការយល់ដឹងអំពី អវប
- បញ្ជីសហគមន៍សិក្សាវិជ្ជាជីវៈ សម្រាប់ការចូលរួម ដើម្បីទទួលបានក្រេឌីត អវប
- គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងឯកសារ អវប ដូចជា សៀវភៅកត់ត្រា អវប ផែនការសិក្សាវិជ្ជាជីវៈ កម្រងស្នាដៃវិជ្ជាជីវៈជាដើម។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥.២ ដំណើរការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមប្រព័ន្ធអនឡាញ

ការិយាល័យគ្រប់គ្រង អវប មានគេហទំព័រ និងកម្មវិធីទូរស័ព្ទដៃដែលគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំអាចចូលមើលដោយផ្ទាល់។ គេហទំព័រនេះផ្តល់លទ្ធភាពឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ អាចបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រង និងការធ្វើផែនការអភិវឌ្ឍវិជ្ជាជីវៈ និងគាំទ្រដល់ការឡើងឋានៈវិជ្ជាជីវៈ។ តាមរយៈគេហទំព័រ ឬកម្មវិធីក្នុងទូរស័ព្ទនេះ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំអាចៈ

- ចូលមើលកម្រងព័ត៌មានផ្ទាល់ខ្លួនដូចជា គុណវុឌ្ឍិ បទពិសោធន៍វិជ្ជាជីវៈ លទ្ធផលនៃការវាយតម្លៃ និងក្រេឌីត អវប ជាដើម
- ផ្ទៀងផ្ទាត់ព័ត៌មានផ្ទាល់ខ្លួន និងដាក់សំណើសុំឱ្យមានការកែតម្រូវទៅតាមការសមស្រប
- ធ្វើការគណនាពិន្ទុ ដើម្បីធ្វើការសម្រេចចិត្តក្នុងការស្នើសុំឱ្យមានការវាយតម្លៃ ឡើងឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន
- ស្នើសុំវិញ្ញាបនបត្រ អវប ដែលបានចូលរួមប្រកបដោយជោគជ័យនៅក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ឬទៅតាមការចាំបាច់
- ពិនិត្យមើលប្រតិទិនសកម្មភាព អវប ទៅតាមមុខវិជ្ជា ឬទីកន្លែង និងចុះឈ្មោះចូលរួមនៅក្នុងសកម្មភាព អវប ជាក់លាក់។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឯកសារយោង


Gathumbi, A.W., Mungai, N.J. & Hintze, D.L. (2013). "Towards Comprehensive Professional Development of Teachers: The Case of Kenya". *International Journal of Process Education*, Volume 5, Issue 1.

MoEYS. (2010). Teacher Professional Standards (2010). Phnom Penh: MoEYS

MoEYS. (2011) Competency Standards for Directors of Teacher Training Colleges. Phnom Penh: MoEYS.

MoEYS. (2016) Teacher Education Provider Standards. Phnom Penh: MoEYS MoEYS. (2017) School Director Professional Standards. Phnom Penh: MoEYS

MoEYS. (2019). Continuous Professional Development Framework for Teachers and School Directors. Phnom Penh: MoEYS

SEA-TCF. (2018) Southeast Asia Teachers Competency Framework. Teachers' Council of Thailand, Bangkok, Thailand.

SEAMEO. (2009) Competency Framework for Southeast Asian Teachers of the 21st Century. Philippines: SEAMEO INNOTECH

SIREP. (2010) Teacher Competency Standards in Southeast Asian Countries. Philippines: SEAMEO INNOTECH

## ឧបសម្ព័ន្ធ

### ១. ឧបករណ៍វាយតម្លៃតម្រូវការ អវប សម្រាប់គ្រូបង្រៀន

កម្រងសំណួរនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់ និងរៀបចំសកម្មភាព អវប សំដៅលើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងវាយតម្លៃលើតម្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់អ្នក។ សូមបំពេញកម្រងសំណួរនេះជាលក្ខណៈបុគ្គលដោយយកចិត្តទុកដាក់ និងស្មោះត្រង់។ ផ្អែកតាមលទ្ធផលនៃការវិភាគ នឹងមានការផ្តល់អនុសាសន៍អំពីសកម្មភាព អវប និងមានការរៀបចំ ឬស្វែងរកឱកាស អវប ដើម្បីឆ្លើយតបចំពោះតម្រូវការទាំងនេះ។

សូមបំពេញកម្រងសំណួរនេះ និងផ្ញើមកវិញឱ្យបានត្រឹមថ្ងៃទី……… ខែ………… ឆ្នាំ…………។

១. ឈ្មោះសាលារៀន៖ ………………………………………

កម្រិតសិក្សា៖ មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ (សូមគូសរង្វង់ជុំវិញ)

ឈ្មោះគ្រូបង្រៀន៖ ……………………………………………………… ភេទ៖ ស្រី ប្រុស (សូមគូសរង្វង់ជុំវិញ)

សញ្ញាបត្រខ្ពស់បំផុត៖……………………………………………………មុខវិជ្ជា៖ ………………………………………………

សញ្ញាបត្រគ្រូបង្រៀន៖ ………………………………………………… មុខវិជ្ជា៖ ………………………………………………

មុខវិជ្ជាកំពុងបង្រៀន៖…………………………………………………………………………………………………………

មុខវិជ្ជា ឬប្រធានបទដែលត្រូវការបណ្តុះបណ្តាលបន្ថែម៖

(១) ……………………………………………………………………………………………………………………………

(២) ……………………………………………………………………………………………………………………………

ចំនួនឆ្នាំបង្រៀន៖..............................

**ផ្នែក ក**

តើលោក លោកស្រីគិតថា ចាំបាច់ត្រូវបង្កើនចំណេះដឹង និងជំនាញជុំវិញប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែរឬទេ? (សូមជ្រើសរើសចម្លើយរហូតដល់ ៦ ពោលគឺអាទិភាពទី១ ចំនួន៣ និងអាទិភាពទី២ ចំនួន៣)

| ប្រធានបទ ចំណេះដឹង ឬជំនាញវិជ្ជាជីវៈ | អាទិភាពទី១ | អាទិភាពទី២ |
|---|---|---|
| ការគ្រប់គ្រងថ្នាក់រៀន | | |
| ការកត់ត្រាការរីកចម្រើនរបស់សិស្ស និងការវាយតម្លៃជាប្រចាំ | | |
| គោលវិធីសិស្សមជ្ឈមណ្ឌល | | |
| ការបង្រៀន និងរៀនតាមបែបរិះរក | | |
| ការអប់រំបរិយាបន្ន | | |
| អំណានថ្នាក់ដំបូង | | |

| | | |
|---|---|---|
| គណិតវិទ្យាថ្នាក់ដំបូង | | |
| ទំនាញសួរ | | |
| ភាសាខ្មែរ | | |
| ភាសាអង់គ្លេស | | |
| ការប្រាស្រ័យទាក់ទងជាមួយមាតាបិតាសិស្ស និងគ្រួសារសិស្ស | | |
| ការប្រើប្រាស់បច្ចេកវិទ្យា ICT សម្រាប់ថ្នាក់រៀន | | |
| ជំនាញអ៊ីនធឺណេត | | |
| ការស្រាវជ្រាវប្រតិបត្តិ | | |
| ការអភិវឌ្ឍពុទ្ធិកុមារ | | |
| ការផលិតសម្ភារៈសិក្សា | | |
| ការបង្រៀនតាមរយៈរឿង និងរឿងព្រេង | | |
| ការបង្រៀននៅក្នុងបរិស្ថានសិក្សាដែលមានធនធានតិចតួច | | |

**ផ្នែក ខ**

តើចំណេះដឹង ឬជំនាញដទៃទៀតណាខ្លះ ដែលលោក លោកស្រីចង់អភិវឌ្ឍបន្ថែមទៀត?

..........................................................................................................................................................

..........................................................................................................................

**ផ្នែក គ (ត្រូវបំពេញដោយអ្នកគ្រប់គ្រងផ្ទាល់)**

ផ្នែកបន្ថែមដែលលោក លោកស្រីគ្រប់គ្រងផ្ទាល់ចាត់ទុកថាចាំបាច់ត្រូវមានការអភិវឌ្ឍវិជ្ជាជីវៈ៖

..........................................................................................................................................................

..........................................................................................................................

យោបល់របស់លោក លោកស្រីគ្រប់គ្រងផ្ទាល់ពាក់ព័ន្ធនឹងជំនាញ និងចំណេះដឹងដែលគ្រូបង្រៀនកំណត់ថាត្រូវការ ការអភិវឌ្ឍវិជ្ជាជីវៈ៖

..........................................................................................................................................................

..........................................................................................................................

ហត្ថលេខាអ្នកគ្រប់គ្រងផ្ទាល់.................................... ហត្ថលេខាគ្រូបង្រៀន ................................

ឈ្មោះអ្នកគ្រប់គ្រងផ្ទាល់........................................ ឈ្មោះគ្រូបង្រៀន ....................................

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២. ឧបករណ៍វាយតម្លៃតម្រូវការ អវប សម្រាប់នាយកសាលា

កម្រងសំណួរនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់ និងរៀបចំសកម្មភាព អវប សំដៅលើកកម្ពស់សមត្ថភាព នាយកសាលា និងវាយតម្លៃលើតម្រូវការអភិវឌ្ឍវិជ្ជាជីវៈ។ សូមបំពេញកម្រងសំណួរនេះជាលក្ខណៈបុគ្គលដោយយកចិត្តទុកដាក់ និងស្មោះត្រង់។ ផ្អែកតាមលទ្ធផលនៃការវិភាគ នឹងមានការផ្ដល់អនុសាសន៍អំពីសកម្មភាព អវប និងមានការរៀបចំឬស្វែងរកឱកាស អវប ដើម្បីឆ្លើយតបចំពោះតម្រូវការទាំងនេះ។

សូមបំពេញកម្រងសំណួរនេះ និងផ្ញើមកវិញឱ្យបានត្រឹមថ្ងៃទី……… ខែ………… ឆ្នាំ…………។

ឈ្មោះសាលារៀន៖ ……………………………………

ប្រភេទសាលារៀន៖ មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ (សូមគូសរង្វង់ជុំវិញ)

ឈ្មោះនាយកសាលា៖ ……………………………………………………… ភេទ៖ ស្រី / ប្រុស (សូមគូសរង្វង់ជុំវិញ)

សញ្ញាបត្រខ្ពស់បំផុត៖…………………………………………………មុខវិជ្ជា៖ …………………………………………

សញ្ញាបត្រគ្រូបង្រៀន៖ ……………………………………………… មុខវិជ្ជា៖ …………………………………………

មុខវិជ្ជាកំពុងបង្រៀន៖…………………………………………………………………………………………………

សញ្ញាបត្រឬវិញ្ញាបនបត្រជាអ្នកគ្រប់គ្រងសាលារៀន៖ ……………………………………………………………

មុខវិជ្ជាឯកទេស៖ …………………………………………………………………………………………………

មុខវិជ្ជា ឬប្រធានបទដែលអ្នកគិតថា អ្នកត្រូវការការបណ្ដុះបណ្ដាលបន្ថែម៖

(១) …………………………………………………………………………………………………………

(២) …………………………………………………………………………………………………………

ចំនួនឆ្នាំបង្រៀន៖ ………………………………

ចំនួនឆ្នាំដែលកាន់តួនាទីជាអ្នកគ្រប់គ្រងសាលារៀន៖ ………………………

**ផ្នែក ក**

តើលោក លោកស្រីគិតថា ចាំបាច់ត្រូវបង្កើនចំណេះដឹង និងជំនាញជុំវិញប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែរឬទេ? (សូមជ្រើសរើសចម្លើយរហូតដល់ ៦ ពោលគឺអាទិភាពចំនួន៣ និងអ្វីដែលចង់រៀនចំនួន៣)

| ប្រធានបទ ចំណេះដឹង ឬជំនាញវិជ្ជាជីវៈ | អាទិភាព | អ្វីដែលចង់រៀន |
|---|---|---|
| ចំណេះដឹងអំពីក្រមសីលធម៌វិជ្ជាជីវៈ | | |
| ភាពជាអ្នកដឹកនាំ | | |
| ការប្ដេជ្ញាចិត្តចំពោះសាលារៀន គ្រូបង្រៀន និងសិស្ស | | |
| ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន | | |

| | | |
|---|---|---|
| ការរៀបចំនិងអនុវត្តចក្ខុវិស័យ និងផែនការសកម្មភាព | | |
| ស្វ័យវាយតម្លៃ និងការគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន | | |
| ការគ្រប់គ្រងរដ្ឋបាលសាលារៀន | | |
| ការគ្រប់គ្រង ការគាំទ្រ និងការវាយតម្លៃបុគ្គលិក | | |
| ការគ្រប់គ្រងហិរញ្ញវត្ថុ | | |
| ការដឹកនាំ និងគ្រប់គ្រងការបង្រៀននិងរៀន | | |
| ការដឹកនាំ និងការគាំទ្រកម្មវិធីសិក្សា | | |
| ការស្រាវជ្រាវ | | |
| ការគ្រប់គ្រងក្រុម និងការគាំទ្រដល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈ | | |
| អធិការកិច្ចផ្ទៃក្នុង | | |
| ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ | | |
| បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ | | |
| ភាសាអង់គ្លេស | | |
| ប្រធានបទផ្សេងទៀតយោងតាមការចាំបាច់៖<br>១.<br>២.<br>៣. | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ផ្នែក ខ**

តើចំណេះដឹង ឬជំនាញដទៃទៀតណាខ្លះក្រៅពីប្រធានបទខាងលើ ដែលលោក លោកស្រីចង់អភិវឌ្ឍបន្ថែមទៀត?

..................................................................................................................................................

..................................................................................................................................................

**ផ្នែក គ (ត្រូវបំពេញដោយអ្នកគ្រប់គ្រងផ្ទាល់)**

ចំណេះដឹង ឬជំនាញបន្ថែមដែលអ្នកគ្រប់គ្រងផ្ទាល់ចាត់ទុកថាចាំបាច់ ត្រូវមានការអភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

យោបល់របស់អ្នកគ្រប់គ្រងផ្ទាល់ពាក់ព័ន្ធនឹងចំណេះដឹង និងជំនាញដែលនាយកសាលាកំណត់ថាត្រូវការ អភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

ហត្ថលេខាអ្នកគ្រប់គ្រងផ្ទាល់..................................... ហត្ថលេខានាយកសាលា.............................

ឈ្មោះអ្នកគ្រប់គ្រងផ្ទាល់ ........................................ ឈ្មោះនាយកសាលា .................................

## ៣. កម្រងស្នាដៃវិជ្ជាជីវៈ

ផ្នែកនេះពិពណ៌នាពីកម្រងស្នាដៃវិជ្ជាជីវៈ និងឧទាហរណ៍ពីខ្លឹមសារនៃកម្រងស្នាដៃវិជ្ជាជីវៈ។ កម្រងស្នាដៃវិជ្ជាជីវៈប្រមូលភស្តុតាងពីការអភិវឌ្ឍវិជ្ជាជីវៈ និងស្នាដៃវិជ្ជាជីវៈរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំនៅក្នុងរយៈពេលមួយ។ កម្រងស្នាដៃវិជ្ជាជីវៈអនុញ្ញាតឱ្យយើងធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលយើងបានធ្វើ ចងក្រងទុកជាឯកសារអំពីការអនុវត្តដែលយើងបានបន្តធ្វើ និងបង្ហាញពីចំណុចទាំងនេះទៅកាន់អ្នកដទៃទៀតដូចជាសហការី និងអ្នកគ្រប់គ្រងជាដើម។

កម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អាជីពបង្រៀន គឺជាការកត់ត្រាដ៏ប្រុងប្រយ័ត្នពីការអភិវឌ្ឍ និងស្នាដៃវិជ្ជាជីវៈនៅក្នុងរយៈពេលណាមួយ។ កម្រងស្នាដៃវិជ្ជាជីវៈ អាចបញ្ចូលចំណុចដូចខាងក្រោម៖

1. **ព័ត៌មានសាវតារ**
   - ប្រវត្តិរូប
   - ព័ត៌មានសាវតារអំពីគ្រូបង្រៀន និងបរិបទនៃការបង្រៀន
   - ទស្សនវិជ្ជាអប់រំ និងគោលដៅនៃការបង្រៀន
2. **ការប្រមូលចងក្រងទុកជាឯកសារពីសម្ភារឧបទ្ទេស និងការឆ្លុះបញ្ចាំងពីការបង្រៀនឬពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈនៅក្នុងរយៈពេលណាមួយ**
   - ការរៀបរាប់ជាទូទៅអំពីវត្ថុបំណងរបស់មេរៀន និងផែនការបង្រៀនសម្រាប់មេរៀនណាមួយ
   - បញ្ជីវាយនាមធនធានដែលត្រូវប្រើប្រាស់នៅក្នុងមេរៀន
   - កិច្ចតែងការបង្រៀនពីរជាប់គ្នា
   - វីដេអូការបង្រៀន
   - ឧទាហរណ៍ពីការងាររបស់សិស្ស
   - ការវាយតម្លៃលើការងាររបស់សិស្ស
   - មូលវិចារឆ្លុះបញ្ចាំងរបស់គ្រូបង្រៀន
   - កំណត់ហេតុនៃការបង្រៀន និងការឆ្លុះបញ្ចាំង
   - មេរៀនឬការងាររបស់សិស្សបន្ថែមទៀតទៅតាមការសមស្រប
3. **ព័ត៌មានវិជ្ជាជីវៈ និងសម្ភារឯកសារដែលបានប្រើប្រាស់កន្លងមក**
